លេខចុះបញ្ជីពាណិជ្ជកម្ម៖
០០០០៣០០៨

# ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី
**( ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា )**

# របាយការណ៍ហិរញ្ញវត្ថុ
# និង
# របាយការណ៍របស់សវនករឯករាជ្យ
# សម្រាប់ការិយបរិច្ឆេទ
# ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

(របាយការណ៍ជាភាសាខ្មែរនេះត្រូវបានបកប្រែចេញពីរបាយការណ៍ភាសាអង់គ្លេស។ ប្រសិនបើការបកប្រែមានភាពខុសគ្នានឹងរបាយការណ៍ជាភាសាអង់គ្លេសសូមយករបាយការណ៍ជាភាសាអង់គ្លេសជាគោល។)

លេខចុះបញ្ជីពាណិជ្ជកម្ម៖
០០០០៣០០៨

**ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## ព័ត៌មានអំពីក្រុមហ៊ុន

| | |
|---|---|
| ក្រុមប្រឹក្សាភិបាល៖ | ឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី<br>លោក ឡុង ពិសី<br>លោក គង់ វ៉ាវ៉ា |
| ទីស្នាក់ការ៖ | ផ្ទះលេខ ១៣២ ផ្លូវលេខ ១៩៣ កែងផ្លូវ ៣៥៨<br>សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន<br>រាជធានីភ្នំពេញ<br>ព្រះរាជាណាចក្រកម្ពុជា |
| ធនាគារចម្បង៖ | ធនាគារជាតិនៃកម្ពុជា<br>ធនាគារអេស៊ីលីដា ភីអិលស៊ី<br>ធនាគារហ្វីលីព ភីអិលស៊ី<br>ធនាគារព្រីនស៍ ភីអិលស៊ី<br>ធនាគារអភិវឌ្ឍន៍ជនបទ |
| សវនករ៖ | ប៊ី ឌី អូ (ខេមបូឌា) លីមីធីត |

លេខចុះបញ្ជីពាណិជ្ជកម្ម៖
០០០០៣០០៨

**ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

**មាតិកា** **ទំព័រ**


| | |
|---|---|
| របាយការណ៍របស់ក្រុមប្រឹក្សាភិបាល | ១ - ៤ |
| របាយការណ៍របស់សវនករឯករាជ្យ | ៥ - ៨ |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ | ៩ - ១០ |
| របាយការណ៍លទ្ធផល | ១១ |
| របាយការណ៍ស្តីពីបម្រែបម្រួលមូលធន | ១២ - ១៣ |
| របាយការណ៍លំហូរសាច់ប្រាក់ | ១៤ - ១៥ |
| កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ | ១៦ - ៤៧ |

**ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល សូមដាក់នូវរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន ព្រមទាំងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់ ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី ហៅកាត់ថា ("ក្រុមហ៊ុន") សម្រាប់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩។

### សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី គឺផ្តល់សេវាឥណទាន និងសេវាកម្មហិរញ្ញវត្ថុផ្សេងៗដល់គ្រួសារដែលមានចំណូលទាបនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ពុំមានការផ្លាស់ប្តូរជា សារវន្តសម្រាប់សកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុនក្នុងកំឡុងការិយបរិច្ឆេទនេះទេ។

### លទ្ធផលនៃប្រតិបត្តិការ

| | ដុល្លារអាមេរិក | ពាន់រៀល |
|---|---|---|
| ចំណេញសម្រាប់ការិយបរិច្ឆេទ | ៧៦.៥៥៦ | ៣១១.៩៦៥ |

### ភាគលាភ

ការបែងចែកភាគលាភនៅក្នុងការិយបរិច្ឆេទនេះ មានដូចខាងក្រោម៖

| | ដុល្លារអាមេរិក |
|---|---|
| សម្រាប់ការិយបរិច្ឆេទ ថ្ងៃ៣១ ខែធ្នូ ឆ្នាំ២០១៧៖ | |
| ភាគលាភដែលមានតម្លៃ 0,0១៦ដុល្លាររអាមេរិក ក្នុងមួយភាគហ៊ុនត្រូវបានទូទាត់នៅថ្ងៃទី៣ ខែតុលា ឆ្នាំ២០១៩ | ៤៦.៨៩០ |
| សម្រាប់ការិយបរិច្ឆេទ ថ្ងៃ៣១ ខែធ្នូ ឆ្នាំ២០១៨៖ | |
| ភាគលាភដែលមានតម្លៃ 0,0១៦ដុល្លាររអាមេរិក ក្នុងមួយភាគហ៊ុនត្រូវបានទូទាត់នៅថ្ងៃទី៣ ខែតុលា ឆ្នាំ២០១៩ | ៤៧.២១៨ |
| | ៩៤.១០៨ |

### ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តទៅលើទុនបម្រុង និងសំវិធានធននៅក្នុងកំឡុងការិយបរិច្ឆេទនេះទេ។

### ឥណទានអាក្រក់ និង ឥណទានជាប់សង្ស័យ

នៅមុនពេលដែលរបាយការណ៍លទ្ធផល និងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុត្រូវបានរៀបចំឡើងក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថា វិធានការទាក់ទងនឹងការលុបចោលនូវឥណទានអាក្រក់ និងការធ្វើសំវិធានធនចំពោះឥណទានជាប់សង្ស័យត្រូវបានធ្វើឡើង ហើយមានការជឿជាក់ថាឥណទានអាក្រក់ ត្រូវបានជម្រះចេញពីបញ្ជី និងសំវិធានធនគ្រប់គ្រាន់ត្រូវបានធ្វើឡើងសម្រាប់ឥណទានសង្ស័យ។

នៅថ្ងៃការិយបរិច្ឆេទនៃរបាយការណ៍នេះក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលនឹងបណ្តាលឱ្យការជម្រះចេញពីបញ្ជីនៃឥណទានអាក្រក់ ឬក៏សំវិធានធនចំពោះឥណទានជាប់សង្ស័យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមានភាពមិនគ្រប់គ្រាន់ជាសារវន្តឡើយ។

លេខចុះបញ្ជីពាណិជ្ជកម្ម:
០០០០៣០០៨



**ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

**របាយការណ៍ក្រុមប្រឹក្សាភិបាល (ត)**

**ទ្រព្យសកម្មចរន្ត**

នៅមុនពេលរបាយការណ៍លទ្ធផល និងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការ ដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មទាំងឡាយណា ដែលទំនងជាមិនអាចបង្វិលមកវិញបានក្នុងប្រតិបត្តិការអាជីវកម្មធម្មតាដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន ត្រូវបានកាត់បន្ថយឱ្យនៅស្មើនឹងតម្លៃដែលរំពឹងទុកថានឹងអាចលក់បាននៅលើទីផ្សារ។

នៅថ្ងៃការិយបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងបណ្តាលឱ្យមានការភ័ន្តច្រឡំដល់ការកំណត់តម្លៃទ្រព្យសកម្មនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនថាមានភាពមិនត្រឹមត្រូវឡើយ។

**វិធីសាស្ត្រកំណត់តម្លៃ**

នៅថ្ងៃការិយបរិច្ឆេទនៃរបាយការណ៍នេះក្រុមប្រឹក្សាភិបាល ពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើង និងបណ្តាលឱ្យមានការភ័ន្តច្រឡំ ឬមានភាពមិនត្រឹមត្រូវដល់វិធីសាស្ត្រកំណត់តម្លៃដែលបានអនុវត្តកន្លងមកលើទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ។

**បំណុលយថាហេតុ និងបំណុលផ្សេងៗ**

នៅថ្ងៃការិយបរិច្ឆេទនៃរបាយការណ៍នេះពុំមាន៖

(១) បន្ទុកណាមួយលើទ្រព្យសកម្មរបស់ក្រុមហ៊ុន ដែលបានកើតឡើងដោយសារការដាក់បញ្ចាំសម្រាប់ការធានាចំពោះបំណុលរបស់បុគ្គលណាមួយចាប់តាំងពីដំណាច់ឆ្នាំឡើយ ឬ

(២) បំណុលយថាហេតុណាមួយរបស់ក្រុមហ៊ុន ដែលបានកើតឡើងតាំងពីដំណាច់ឆ្នាំនេះឡើយ។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗដែលត្រូវបានទាមទារឱ្យសងក្នុងរយៈពេល១២ខែ បន្ទាប់ពីថ្ងៃដំណាច់ឆ្នាំ ដែលនឹង ឬអាចមានការប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅថ្ងៃដល់កំណត់សងនោះទេ។

**ការផ្លាស់ប្តូរនៃហេតុការណ៍**

នៅថ្ងៃការិយបរិច្ឆេទនៃរបាយការណ៍នេះក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលបានកើតឡើងពាក់ព័ន្ធនឹងរបាយការណ៍នេះ ឬរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលអាចបណ្តាលឱ្យមានចំនួនទឹកប្រាក់ដែលបានបង្ហាញក្នុងរបាយការណ៍របស់ក្រុមហ៊ុនមានកំហុសឆ្គងធ្ងន់ធ្ងរនោះទេ។

**ប្រតិបត្តិការមិនប្រក្រតី**

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល លទ្ធផលនៃប្រតិបត្តិការអាជីវកម្មរបស់ក្រុមហ៊ុនក្នុងកំឡុងការិយបរិច្ឆេទនេះមិនបានទទួលរងនូវផលប៉ះពាល់ជាសារវន្តពីខ្ទង់គណនី ប្រតិបត្តិការ ឬព្រឹត្តិការណ៍ខុសប្រក្រតីណាមួយឡើយ។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល នៅចន្លោះចុងការិយបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុរហូតមកទល់នឹងថ្ងៃចេញរបាយការណ៍នេះ មិនមានខ្ទង់គណនីប្រតិបត្តិការ ឬព្រឹត្តិការណ៍ខុសប្រក្រតីណាមួយ ដែលអាចជះឥទ្ធិពលជាសារវន្តដល់លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនក្នុងកំឡុងការិយបរិច្ឆេទនេះទេ។

លេខចុះបញ្ជីពាណិជ្ជកម្ម:
០០០០៣០០៨



**ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ក្រុមប្រឹក្សាភិបាល (ត)

### ដើមទុន

ក្រុមហ៊ុនមិនបានបោះផ្សាយភាគហ៊ុនថ្មីនៅចុងការិយបរិច្ឆេទនេះទេ។

ក្រុមហ៊ុនពុំមានកិច្ចសន្យាផ្តល់ភាគហ៊ុនមិនទាន់បោះផ្សាយ និងមិនមានភាគហ៊ុនក្រោមកិច្ចសន្យាផ្តល់សិទ្ធជាភាគហ៊ុននៃក្រុមហ៊ុននាចុងការិយបរិច្ឆេទនេះទេ។

### សមាជិកក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលដែលបាននៅបម្រើការចាប់តាំងពីរបាយការណ៍ចុងក្រោយមានរាយនាមដូចខាងក្រោម៖

ឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី

លោក ឡុង ពិសី

លោក គង់ វ៉ាវ៉ា

### អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

ក្នុងកំឡុងពេល និងចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះក្រុមហ៊ុនមិនបានចូលរួមជាភាគីក្នុងការរៀបចំណាមួយក្នុងគោលបំណងជួយដល់សមាជិកក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ឱ្យទទួលបាននូវផលប្រយោជន៍ផ្សេងៗតាមរយៈការទិញភាគហ៊ុន ឬប័ណ្ណបំណុលពីសាមីក្រុមហ៊ុន ឬក្រុមហ៊ុនផ្សេងឡើយ។

ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុនៃការិយបរិច្ឆេទកន្លងទៅ ក្រុមប្រឹក្សាភិបាលពុំបានទទួល ឬមានសិទ្ធិទទួល នូវអត្ថប្រយោជន៍ណាមួយតាមរយៈការចុះកិច្ចសន្យាដែលបានធ្វើឡើងរវាង ក្រុមហ៊ុន ឬរវាងក្រុមហ៊ុនដែលសមាជិកក្រុមប្រឹក្សាភិបាលនោះជាសមាជិក ឬក៏រវាងក្រុមហ៊ុនដែលសមាជិកក្រុមប្រឹក្សាភិបាលនោះមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុជាសារវន្តនោះទេ លើកលែងតែចំពោះអត្ថប្រយោជន៍ ដែលបានបង្ហាញដូចក្នុងកំណត់សម្គាល់ទី២៩ក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

### ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានភារកិច្ចធ្វើការបញ្ជាក់រះរវាងថារបាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើង ដើម្បីបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ និងលទ្ធផលនៃប្រតិបត្តិការព្រមទាំងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទនេះ។ ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះក្រុមប្រឹក្សាភិបាលត្រូវ ៖

ក. ជ្រើសរើសគោលការណ៍គណនេយ្យសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្ន ព្រមទាំងអនុវត្តតាមគោលការណ៍ទាំងនេះឱ្យបានជាប់លាប់។

ខ. អនុលោមទៅតាមគោលការណ៍ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់អង្គភាពធុនតូច និងមធ្យម ហៅកាត់ថា ("ស.រ.ហ.អ.ក.ស.ធ.ត.ម") និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ឬប្រសិនបើមានការប្រាសចាកណាមួយក្នុងការបង្ហាញនូវភាពពិត និងត្រឹមត្រូវ ក្រុមប្រឹក្សាភិបាលត្រូវប្រាកដថាការប្រាសចាកទាំងនេះត្រូវបានលាតត្រដាងពន្យល់ និងកំណត់បរិមាណឱ្យបានត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

គ. រក្សាទុកកំណត់ត្រាគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព។

ឃ. រៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្មលើកលែងតែក្នុងករណីសន្មតយ៉ាងសមរម្យថាក្រុមហ៊ុននឹងមិនអាចបន្តធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួននាពេលអនាគតដ៏ខ្លី និង

លេខចុះបញ្ជីពាណិជ្ជកម្ម:
០០០០៣០០៨



**ប្រសិទ្ធភាព ហ្វាយនែន មីរ៉ូហ្វាយនែន ភីអិលស៊ី**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

**របាយការណ៍ក្រុមប្រឹក្សាភិបាល (ត)**

**ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ (ត)**

ក្រុមប្រឹក្សាភិបាលមានភារកិច្ចធ្វើការបញ្ជាក់អះអាងថារបាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើង ដើម្បីបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ និងលទ្ធផលនៃប្រតិបត្តិការព្រមទាំងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទនេះ។ ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះក្រុមប្រឹក្សាភិបាលត្រូវ (ត)៖

ង. គ្រប់គ្រង និងដឹកនាំក្រុមហ៊ុនឱ្យមានប្រសិទ្ធភាព និងចូលរួមក្នុងការសម្រេចចិត្តសំខាន់ៗទាំងអស់ដែលមានឥទ្ធិពលជាសារវន្តលើប្រតិបត្តិការ ហើយត្រូវប្រាកដថាការសម្រេចចិត្តលើកិច្ចការទាំងនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលអះអាងថាក្រុមហ៊ុនបានអនុវត្តតាមនូវរាល់តម្រូវការខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

**ព្រឹត្តិការណ៍សំខាន់ៗបន្ទាប់ពីការបញ្ចប់រយៈពេលនៃរបាយការណ៍**

ព្រឹត្តិការណ៍សំខាន់ៗបន្ទាប់ពីការបញ្ចប់រយៈពេលនៃរបាយការណ៍ត្រូវបានបង្ហាញក្នុង កំណត់សម្គាល់ទី៣២នៃរបាយការណ៍ហិរញ្ញវត្ថុ។

**សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល**

តាមទស្សនៈរបស់ក្រុមប្រឹក្សាភិបាល របាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់ចាប់ពីទំព័រទី៩ ដល់ ៤៧ បានបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ និងលទ្ធផលនៃប្រតិបត្តិការព្រម ទាំងលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់អង្គភាពធុនតូច និងមធ្យម និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា។

តាងនាមឱ្យក្រុមប្រឹក្សាភិបាល

ឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី
ប្រធានក្រុមប្រឹក្សាភិបាល

លោក ម៉ុក ណាច
អគ្គនាយក

រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០

BDO

Tel: +855 23 218 128
Fax:+855 23 993 225
www.bdo.com.kh

Suite 28 Hotel Cambodiana
313 Sisowath Quay
Phnom Penh
Kingdom of Cambodia



## សេចក្ដីរាយការណ៍របស់សវនករឯករាជ្យជូនចំពោះភាគហ៊ុនិកនៃ ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

(លេខចុះបញ្ជី៖ ០០០០៣០០៨)

## សេចក្ដីរាយការណ៍លើរបាយការណ៍ហិរញ្ញវត្ថុ

### មតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី ហៅកាត់ថា ("ក្រុមហ៊ុន") រួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ របាយការណ៍លទ្ធផល របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ព្រមទាំងសេចក្ដីសង្ខេបនៃគោលការណ៍គណនេយ្យសំខាន់ៗ និងកំណត់សម្គាល់ផ្សេងៗទៀត ដែលមានបង្ហាញចាប់ពីទំព័រទី៩ ដល់ ៤៧។

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ត្រូវបានធ្វើសវនកម្មដោយគណនេយ្យករជំនាញមួយផ្សេងទៀត ដែលបានចេញរបាយការណ៍នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩ ដោយបានបញ្ចេញមតិយោបល់ពិត និងត្រឹមត្រូវទៅលើរបាយការណ៍ហិរញ្ញវត្ថុនេះ។

តាមទស្សនៈរបស់យើងខ្ញុំរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ និងលទ្ធផលនៃប្រតិបត្តិការព្រមទាំងលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់អង្គភាពធុនតូច និងមធ្យម និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា។

### មូលដ្ឋានក្នុងការបញ្ចេញមតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ("CISAs")។ កាតព្វកិច្ចរបស់យើងខ្ញុំបានធ្វើតាមស្តង់ដារ ដោយផ្អែកលើទំនួលខុសត្រូវរបស់សវនករឯករាជ្យទៅលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុក្នុងរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបានមានភាពគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិរបស់យើងខ្ញុំ។

### ទំនួលខុសត្រូវឯករាជ្យភាព និងក្រមសីលធម៌

យើងខ្ញុំមានភាពឯករាជ្យពីក្រុមហ៊ុនដោយគោរពទៅតាម *ក្រមសីលធម៌របស់គណនេយ្យករជំនាញ និងសវនករ* នៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា ("Code of Ethic") និង*ក្រមសីលធម៌របស់គណនេយ្យករជំនាញ* ("IESBA Code") របស់ក្រុមប្រឹក្សាភិបាលស្តង់ដារក្រមសីលធម៌អន្តរជាតិសំរាប់គណនេយ្យករជំនាញ ហើយយើងខ្ញុំបានបំពេញនូវទំនួលខុសត្រូវក្រមសីលធម៌ដទៃទៀតទៅតាម ក្រមសីលធម៌របស់គណនេយ្យករជំនាញនេះផងដែរ។

BDO (Cambodia) Limited, Certified Public Accountants, a Cambodian limited liability company, is a member of BDO International Limited, a UK company limited by guarantee, and forms part of the international BDO network of independent member firms.

**សេចក្តីរាយការណ៍របស់សវនករឯករាជ្យជូនចំពោះភាគហ៊ុនិកនៃ**
**ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)
(លេខចុះបញ្ជី៖ ០០០០៣០០៨) (ត)

**ព័ត៌មានក្រៅពីរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍របស់សវនករ**

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវនូវព័ត៌មានផ្សេងទៀត។ ព័ត៌មានដែលមានក្នុងរបាយការណ៍របស់ ក្រុមប្រឹក្សាភិបាល ប៉ុន្តែមិនរួមបញ្ចូលនូវរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងរបាយការណ៍របស់សវនករឯករាជ្យយើងខ្ញុំទេ។

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មិនបានបង្ហាញក្នុងរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល ហើយយើងមិនបានបង្ហាញពីទម្រង់នៃការសន្និដ្ឋានលើការធានាណាមួយឡើយ។

ទាក់ទងជាមួយនឹងការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន យើងខ្ញុំមានកាតព្វកិច្ចក្នុងការតាមដានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល និងការអនុវត្ត ពិចារណាថាតើរបាយការណ៍របស់ក្រុមប្រឹក្សាភិបាលគឺមានភាពជាសារវន្តមិនស្របតាមរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឬការយល់ដឹងរបស់យើងទទួលបានក្នុងសវនកម្ម ឬកំហុសឆ្គងជាសារវន្តត្រូវបានបង្ហាញ។

ប្រសិនបើផ្អែកលើការងារដែលយើងខ្ញុំបានអនុវត្ត យើងខ្ញុំសន្និដ្ឋានថារបាយការណ៍របស់ក្រុមប្រឹក្សាភិបាលមានកំហុសឆ្គងជាសារវន្ត យើងខ្ញុំតម្រូវឱ្យរាយការណ៍ពីការពិត តែយើងខ្ញុំមិនមានអ្វីដើម្បីរាយការណ៍ក្នុងរឿងនេះទេ។

**ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ**

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការរៀបចំ និងបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់អង្គភាពធុនតូច និងមធ្យម និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា។ ក្រុមប្រឹក្សាភិបាលក៏ត្រូវ និងទទួលខុសត្រូវលើ ការត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងកំណត់ថា វាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុមិនឱ្យមានការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ក្រុមប្រឹក្សាភិបាលមានភារកិច្ចធ្វើការវាយតម្លៃពីលទ្ធផលនៃសមត្ថភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាព ការលាតត្រដាង ដូចដែលមានបញ្ហាទាក់ទងទៅនឹងការបន្តនិរន្តរភាព និងការប្រើប្រាស់មូលដ្ឋាននិរន្តរភាពគណនេយ្យ លុះត្រាតែក្រុមប្រឹក្សាភិបាលមានបំណងរំលាយក្រុមហ៊ុន ឬបញ្ឈប់ប្រតិបត្តិការ ឬមិនមានជម្រើសផ្សេងទេដើម្បីធ្វើដូច្នេះបាន។

**ទំនួលខុសត្រូវរបស់សវនករឯករាជ្យលើរបាយការណ៍ហិរញ្ញវត្ថុ**

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបានអំណះអំណាងយ៉ាងសមហេតុផល ថាតើរបាយការណ៍ហិរញ្ញវត្ថុពុំមានកំហុសឆ្គងជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬការភ័ន្តច្រឡំ និងចេញនូវរបាយការណ៍របស់សវនករឯករាជ្យដែលមានការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។ អំណះអំណាងយ៉ាងសមហេតុផល គឺជាអំណះអំណាងកម្រិតខ្ពស់ ប៉ុន្តែមិនអាចធានាថាមតិយោបល់របស់សវនកម្មអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា តែងតែការពារនូវកំហុសឆ្គងជាសារវន្ត នៅពេលកើតមានឡើងនោះទេ។ ភាពខុសឆ្គងដែលបណ្តាលមកពីការក្លែងបន្លំ ឬការភ័ន្តច្រឡំ ត្រូវបានពិចារណាថាជាកំហុសឆ្គងជាសារវន្ត ប្រសិនបើជាលក្ខណៈបុគ្គល ឬជាក្រុម ពួកគេអាចនឹងត្រូវបានគេរំពឹងថាប្រើប្រាស់ឥទ្ធិពលសេដ្ឋកិច្ចក្នុងការគ្រប់គ្រងលើការសម្រេចចិត្តរបស់អ្នកប្រើប្រាស់នៅលើមូលដ្ឋាននៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

## សេចក្តីរាយការណ៍របស់សវនករឯករាជ្យជូនចំពោះភាគហ៊ុនិកនៃ ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

(លេខចុះបញ្ជី៖ ០០០០៣០០៨) (ត)

### ទំនួលខុសត្រូវរបស់សវនករឯករាជ្យលើរបាយការណ៍ហិរញ្ញវត្ថុ (ត)

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងអនុវត្តការវិនិច្ឆ័យដែលមានជំនាញវិជ្ជាជីវៈ និងរក្សាបាននូវការសង្ស័យដែលមានជំនាញវិជ្ជាជីវៈតាមរយៈការធ្វើសវនកម្ម។ យើងបានធ្វើ៖

- កំណត់ និងការវាយតម្លៃហានិភ័យកំហុសឆ្គងជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនថាតើការក្លែងបន្លំ ឬការភ័ន្តច្រឡំ រៀបចំនិងអនុវត្តតាមនីតិវិធីសវនកម្មអាចឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងទទួលបាននូវភស្តុតាងសវនកម្មគ្រប់គ្រាន់ និងសមស្របដើម្បីផ្តល់នូវមូលដ្ឋានក្នុងការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យនៃការមិនរកឃើញកំហុសឆ្គងជាសារវន្ត ជាលទ្ធផលបណ្តាលមកពីការក្លែងបន្លំច្រើនជាងការភ័ន្តច្រឡំ ការក្លែងបន្លំ អាចពាក់ព័ន្ធនឹងការឃុបឃិតគ្នា ការក្លែងបន្លំ ការលុបចោលដោយចេតនា ការបកស្រាយខុស ឬការបដិសេធនៃការត្រួតពិនិត្យផ្ទៃក្នុង។
- វាយតំលៃនូវភាពសមស្របនៃគោលនយោបាយគណនេយ្យ និងការប៉ាន់ស្មានគណនេយ្យសមហេតុផល និងបង្ហាញការទាក់ទងដែលធ្វើឡើងដោយក្រុមប្រឹក្សាភិបាល។
- សេចក្តីសន្និដ្ឋានលើភាពសមស្របនៃការគ្រប់គ្រងលើការប្រើប្រាស់មូលដ្ឋាននិរន្តរភាពគណនេយ្យ និងដោយផ្អែកលើភស្តុតាងសវនកម្មដែលទទួលបាន ថាតើភាពមិនមានច្បាស់លាស់ជាសារវន្តអាចកើតមាន ទាក់ទងទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចសង្ស័យយ៉ាងខ្លាំងលើសមត្ថភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាព។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាភាពមិនមានច្បាស់លាស់ជាសារវន្ត យើងខ្ញុំត្រូវបានទាមទារការយកចិត្តទុកដាក់នៅក្នុងរបាយការណ៍សវនករឯករាជ្យរបស់យើងខ្ញុំ បង្ហាញការទាក់ទងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឬបើការបង្ហាញបែបនេះ គឺមិនគ្រប់គ្រាន់ ដើម្បីកែប្រែមតិយោបល់របស់យើងខ្ញុំទេ។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកលើភស្តុតាងសវនកម្មដែលទទួលបានរហូតដល់កាលបរិច្ឆេទ នៃរបាយការណ៍សវនករឯករាជ្យរបស់យើងខ្ញុំ។ ទោះបីជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគតអាចបង្កឱ្យក្រុមហ៊ុនបញ្ឈប់នូវភាពនិរន្តរភាពបាន។
- ការវាយតម្លៃលើភាពគ្រប់គ្រាន់នៃការបង្ហាញជារួម រចនាសម្ព័ន្ធ និងមាតិកានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួមមានកំណត់បង្ហាញព័ត៌មាន ថាតើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបង្ហាញពីប្រតិបត្តិការ មូលដ្ឋាន និងព្រឹត្តិការណ៍ប្រកបដោយសេចក្តីសម្រេចក្នុងការបង្ហាញនូវភាពត្រឹមត្រូវដែរ ឬទេ។

យើងខ្ញុំទាក់ទងជាមួយក្រុមប្រឹក្សាភិបាលពាក់ព័ន្ធនឹងបញ្ហាដទៃទៀត វិសាលភាពដែលបានគ្រោងទុក និងការកំណត់ពេលវេលានៃការធ្វើសវនកម្ម និងការស្វែងរកការធ្វើសវនកម្មយ៉ាងសំខាន់ រួមបញ្ចូលទាំងកង្វះខាតសំខាន់ណាមួយនៅក្នុងការត្រួតពិនិត្យផ្ទៃក្នុងដែលយើងកត់សម្គាល់ក្នុងកំឡុងពេលធ្វើសវនកម្មរបស់យើងខ្ញុំ។

**សេចក្តីរាយការណ៍របស់សវនករឯករាជ្យជូនចំពោះភាគហ៊ុនិកនៃ**
**ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)
(លេខចុះបញ្ជី៖ ០០០០៣០០៨) (ត)

**បញ្ហាផ្សេងៗ**

របាយការណ៍នេះត្រូវបានធ្វើឡើង សម្រាប់ភាគហ៊ុនិករបស់ក្រុមហ៊ុនតែប៉ុណ្ណោះ។ យើងខ្ញុំនឹងមិនទទួលខុសត្រូវចំពោះខ្លឹមសារនៃរបាយការណ៍នេះ សម្រាប់បុគ្គលផ្សេងទៀតឡើយ។

BDO Cambodia

**ប៊ី ឌី អូ (ខេមបូឌា) លីមីធីត**

រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០

លេខចុះបញ្ជីពាណិជ្ជកម្ម៖
០០០០៣០០៨



## ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
**នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

| | កំណត់សម្គាល់ | ២០១៩ ដុល្លារអាមេរិក | ២០១៩ ពាន់រៀល | ២០១៨ ដុល្លារអាមេរិក (កំណត់ឡើងវិញ) |
|---|---|---|---|---|
| **ទ្រព្យសកម្ម** | | | | |
| សាច់ប្រាក់ក្នុងដៃ | ៦ | ៤០.៤៧០ | ១៦៤.៩១៥ | ៣៨.៦០៤ |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | ៧ | ១៤៧.៤៩៤ | ៦០១.០៣៨ | ១៤៧.០០៤ |
| សមតុល្យនៅធនាគារផ្សេងៗ | ៨ | ៣២៧.៧៨៥ | ១.៣៣៥.៧២៤ | ៤៤.២១៦ |
| ឥណទានទៅអតិថិជន | ៩ | ៤.២២៦.១៨០ | ១៧.២២១.៦៨៤ | ៤.១៧៨.៤៥៩ |
| គណនីត្រូវទទួលផ្សេងៗ | ១០ | ១៦២.៣៣៣ | ៦៦១.៥០៧ | ១៧៧.២៣៥ |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | ១១ | ៨០.១៩៧ | ៣២៦.៨០៣ | ១១៧.៣៤៨ |
| ទ្រព្យសកម្មអរូបី | ១២ | ៣២.៧៩៧ | ១៣៣.៦៤៨ | ១.៦៧៨ |
| ទ្រព្យសកម្មពន្ធពន្យា | ១៣ | ២២.៩៧៧ | ៩៣.៦៣១ | ១៨.៣៩៧ |
| **ទ្រព្យសកម្មសរុប** | | ៥.០៤០.២៣៣ | ២០.៥៣៨.៩៥០ | ៤.៧២២.៩៤១ |
| **បំណុល និងមូលធន** | | | | |
| **បំណុល** | | | | |
| ប្រាក់កម្ចី | ១៤ | ១.៤៧៧.០៣៥ | ៦.០១៨.៩១៨ | ១.០៧៤.០៨៦ |
| គណនីត្រូវបង់ផ្សេងៗ | ១៥ | ៨៦.៤៨០ | ៣៥២.៤០៧ | ១០៨.៤២០ |
| បំណុលពន្ធចរន្ត | | ១៣.១១២ | ៥៣.៤៣១ | ៥៩.២៧៧ |
| **បំណុលសរុប** | | ១.៥៧៦.៦២៧ | ៦.៤២៤.៧៥៦ | ១.២៤១.៧៨៣ |

## ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
**នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ (ត)**

| | កំណត់សម្គាល់ | ២០១៩ ដុល្លារអាមេរិក | ២០១៩ ពាន់រៀល | ២០១៨ ដុល្លារអាមេរិក (កំណត់ឡើងវិញ) |
|---|---|---|---|---|
| **បំណុល និងមូលធន (ត)** | | | | |
| **មូលធន** | | | | |
| ដើមទុន | ១៦ | ២.៩១៥.៧៦៦ | ១១.៨៨១.៧៤៦ | ២.៩១៥.៧៦៦ |
| បុព្វលាភភាគហ៊ុន | | ៦៣.០៧៨ | ២៥៧.០៤៣ | ៦៣.០៧៨ |
| ដើមទុនផ្សេងៗ | ១៧ | ១៩០.០០០ | ៧៧៤.២៥០ | ១៩០.០០០ |
| ទុនបម្រុង | ១៨ | ៨៤.៤៦៨ | ៣៤៤.២០៧ | ៩៦.៦៧៧ |
| ប្រាក់ចំណេញរក្សាទុក | | ២១០.២៩៤ | ៨៥៦.៩៤៨ | ២១៥.៦៣៧ |
| **មូលធនសរុប** | | ៣.៤៦៣.៦០៦ | ១៤.១១៤.១៩៤ | ៣.៤៨១.១៥៨ |
| **បំណុល និងមូលធនសរុប** | | ៥.០៤០.២៣៣ | ២០.៥៣៨.៩៥០ | ៤.៧២២.៩៤១ |

## ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍លទ្ធផល
**សម្រាប់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

| | កំណត់សម្គាល់ | ២០១៩ ដុល្លារអាមេរិក | ២០១៩ ពាន់រៀល | ២០១៨ ដុល្លារអាមេរិក (កំណត់ឡើងវិញ) |
|---|---|---|---|---|
| ចំណូលការប្រាក់ | ១៩ | ៩៣២.០១៩ | ៣.៧៩៧.៩៧៧ | ៨៨៩.៥០៩ |
| ចំណាយការប្រាក់ | ២០ | (១៣៦.៤២៣) | (៥៥៥.៩២៤) | (១១០.០៩៦) |
| ចំណូលការប្រាក់សុទ្ធ | | ៧៩៥.៥៩៦ | ៣.២៤២.០៥៣ | ៧៧៩.៤១៣ |
| សំវិធានធនលើហ្វាស៊ីលីធី | ២១ | (៣០.៨៩៩) | (១២៥.៩១៣) | - |
| ចំណូលប្រតិបត្តិការផ្សេងៗ | ២២ | ១៥.១៧៦ | ៦១.៨៤២ | ១៤.៨៦០ |
| ចំណាយប្រាក់បៀវត្ស | ២៣ | (៤៣៧.១៤៤) | (១.៧៨១.៣៦២) | (៤១២.៣៦៣) |
| ចំណាយរំលស់ | ២៤ | (៤៧.៣៤៥) | (១៩២.៩៣១) | (៤៤.៦៧៩) |
| ចំណាយទូទៅ និងរដ្ឋបាល | ២៥ | (២២៩.០៤៦) | (៩៣៣.៣៦២) | (២០១.២៨៨) |
| ចំណេញមុនដកចំណាយពន្ធ | | ៦៦.៣៣៨ | ២៧០.៣២៧ | ១៣៥.៩៤៣ |
| ចំណាយពន្ធលើប្រាក់ចំណេញ | ២៦ | ១០.២១៨ | ៤១.៦៣៨ | (៥៦.៨៤៧) |
| ប្រាក់ចំណេញក្នុងការិយបរិច្ឆេទ | | ៧៦.៥៥៦ | ៣១១.៩៦៥ | ៧៩.០៩៦ |
| ចំណូលផ្សេងៗ បន្ទាប់ពីគិតពន្ធរួច | | - | - | - |
| ចំណូលផ្សេងៗសរុបក្នុងការិយបរិច្ឆេទ | | ៧៦.៥៥៦ | ៣១១.៩៦៥ | ៧៩.០៩៦ |

*កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយគឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុមួយនេះ។*

**ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

**របាយការណ៍បម្រែបម្រួលមូលធន**
**សម្រាប់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

| | កំណត់សម្គាល់ | ដើមទុន ដុល្លារអាមេរិក | បុព្វលាភភាគហ៊ុន ដុល្លារអាមេរិក | ដើមទុនផ្សេងៗ ដុល្លារអាមេរិក | ទុនបម្រុង ដុល្លារអាមេរិក | ប្រាក់ចំណេញរក្សាទុក ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|---|---|---|---|
| **សមតុល្យនៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៨ ក្នុងរបាយការណ៍មុន** | | **២.៩១៥.៧៦៦** | **៦៣.០៧៨** | **១៩០.០០០** | **៦.៩០១** | **១៥៨.៥៩៧** | **៣.៣៣៤.៣៤២** |
| ផលប៉ះពាល់នៃការអនុវត្ត ស.រ.ហ.អ.ក.ស.ធ.ត.ម | ៣៣ | - | - | - | ៧៦.៣៨៧ | (៨.៦៦៧) | ៦៧.៧២០ |
| **សមតុល្យនៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៨ កំណត់ឡើងវិញ** | | **២.៩១៥.៧៦៦** | **៦៣.០៧៨** | **១៩០.០០០** | **៨៣.២៨៨** | **១៤៩.៩៣០** | **៣.៤០២.០៦២** |
| ចំណេញសរុបក្នុងការិយបរិច្ឆេទ តំណាងដោយចំណូលផ្សេងៗ | | | | | | | |
| សរុប | | - | - | - | - | ៧៩.០៩៦ | ៧៩.០៩៦ |
| **ប្រតិបត្តិការជាមួយភាគហ៊ុនិក** | | | | | | | |
| ការផ្ទេរទៅទុនបម្រុង តំណាងដោយប្រតិបត្តិការជាមួយភាគហ៊ុនិក | | | | | | | |
| សរុប | | - | - | - | ១៣.៣៨៩ | (១៣.៣៨៩) | - |
| **សមតុល្យនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨/ ថ្ងៃទី១ ខែមករា ឆ្នាំ ២០១៩ កំណត់ឡើងវិញ** | | **២.៩១៥.៧៦៦** | **៦៣.០៧៨** | **១៩០.០០០** | **៩៦.៦៧៧** | **២១៥.៦៣៧** | **៣.៤៨១.១៥៨** |

លេខចុះបញ្ជីពាណិជ្ជកម្មៈ
០០០០៣០០៨



# ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី

(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍បម្រែបម្រួលមូលធន

សម្រាប់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩(ត)

| | កំណត់សម្គាល់ | ដើមទុន ដុល្លារអាមេរិក | បុព្វលាភភាគហ៊ុន ដុល្លារអាមេរិក | ដើមទុនផ្សេងៗ ដុល្លារអាមេរិក | ទុនបម្រុង ដុល្លារអាមេរិក | ប្រាក់ចំណេញរក្សាទុក ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|---|---|---|---|
| ចំណេញសរុបក្នុងការិយបរិច្ឆេទ តំណាងដោយចំណូលផ្សេងៗ | | | | | | | |
| សរុប | | - | - | - | - | ៧៦.៥៥៦ | ៧៦.៥៥៦ |
| **ប្រតិបត្តិការជាមួយភាគហ៊ុនិក** | | | | | | | |
| ការផ្ទេរទៅទុនបម្រុង | | - | - | - | (១២.២០៩) | ១២.២០៩ | - |
| ភាគលាភដែលត្រូវបង់ | ២៧ | - | - | - | - | (៩៤.១០៨) | (៩៤.១០៨) |
| **ប្រតិបត្តិការជាមួយភាគហ៊ុនិកសរុប** | | - | - | - | (១២.២០៩) | (៨១.៨៩៩) | (៩៤.១០៨) |
| **សមតុល្យនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩** | | **២.៩១៥.៧៦៦** | **៦៣.០៧៨** | **១៩០.០០០** | **៨៤.៤៦៨** | **២១០.២៩៤** | **៣.៤៦៣.៦០៦** |
| *(គិតជាពាន់រៀល)* | | *១១.៨៨១.៧៤៦* | *២៥៧.០៤៣* | *៧៧៤.២៥០* | *៣៤៤.២០៧* | *៨៥៦.៩៤៨* | *១៤.១១៤.១៩៤* |

*កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយគឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុមួយនេះ។*

**ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

**របាយការណ៍លំហូរសាច់ប្រាក់**
**សម្រាប់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

| | កំណត់សម្គាល់ | ២០១៩ ដុល្លារអាមេរិក | ២០១៩ ពាន់រៀល | ២០១៨ ដុល្លារអាមេរិក (កំណត់ឡើងវិញ) |
|---|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | |
| ចំណេញមុនដកចំណាយពន្ធ | | ៦៦.៣៣៨ | ២៧០.៣២៧ | ១៣៥.៩៤៣ |
| និយ័តកម្ម៖ | | | | |
| សំវិធានធនសម្រាប់ឥណទានជាប់សង្ស័យ | ៩ | ៣០.៨៩៩ | ១២៥.៩១៣ | - |
| រំលស់ទ្រព្យសកម្មអរូបី | ១២ | ៧.៧៩៤ | ៣១.៧៦១ | ១.៩៩០ |
| រំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ | ១១ | ៣៩.៥៥១ | ១៦១.១៧០ | ៤២.៦៨៩ |
| ចំណាយការប្រាក់ | ២០ | ១៣៦.៤២៣ | ៥៥៥.៩២៤ | ១១០.០៩៦ |
| ការជម្រះចេញពីបញ្ជីនៃទ្រព្យសម្បត្តិ និងបរិក្ខារ | | - | - | ១៤៥ |
| ឱនភាពលើឥណទានទៅអតិថិជនដែលបានត្រលប់មកវិញ | ៩ | - | - | (១៤២) |
| ចំណូលប្រតិបត្តិការមុនពេលបម្រែបម្រួលដើមទុនបង្វិល | | ២៨១.០០៥ | ១.១៤៥.០៩៥ | ២៩០.៧២១ |
| បម្រែបម្រួលដើមទុនបង្វិល៖ | | | | |
| ឥណទានទៅអតិថិជន | | (៧៨.៦២០) | (៣២០.៣៧៧) | (១៩៤.០៧២) |
| គណនីត្រូវទទួលផ្សេងៗ | | ១៤.៩០២ | ៦០.៧២៦ | (២២.១២៦) |
| គណនីត្រូវបង់ផ្សេងៗ | | (២៥.៨៨១) | (១០៥.៤៦៦) | ៦៣.៦១៦ |
| សាច់ប្រាក់បានមកពីសកម្មភាពប្រតិបត្តិការ | | ១៩១.៤០៦ | ៧៧៩.៩៧៨ | ១៣៨.១៣៩ |
| ពន្ធដែលបានបង់ | | (១៣២.៤៨២) | (៥៣៩.៨៦៤) | (១០៤.៦៧៩) |
| ការប្រាក់ដែលបានបង់ | | (៤០.៥២៧) | (១៦៥.១៤៨) | (១៧.១៥០) |
| សាច់ប្រាក់សុទ្ធទទួលបានពីសកម្មភាពប្រតិបត្តិការ | | ១៨.៣៩៧ | ៧៤.៩៦៦ | ១៦.៣១០ |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | |
| ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ | ១១ | (២.៤០០) | (៩.៧៨០) | (៦.៦៨៨) |
| ការទិញទ្រព្យសកម្មអរូបី | ១២ | (៣៨.៩១៣) | (១៥៨.៥៧០) | - |
| សាច់ប្រាក់សុទ្ធដែលប្រើក្នុងសកម្មភាពវិនិយោគ | | (៤១.៣១៣) | (១៦៨.៣៥០) | (៦.៦៨៨) |

## ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍លំហូរសាច់ប្រាក់
**សម្រាប់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩(ត)**

| | កំណត់ សម្គាល់ | ២០១៩ ដុល្លារអាមេរិក | ២០១៩ ពាន់រៀល | ២០១៨ ដុល្លារអាមេរិក (កំណត់ឡើងវិញ) |
|---|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញវត្ថុ** | | | | |
| ការបន្ថែមប្រាក់កម្ចី | | (៩២៤.០៨៦) | (៣.៧៦៥.៦៥០) | (២.១១៣.៣០៦) |
| ការសងប្រាក់កម្ចី | | ១.៣២៧.០៣៥ | ៥.៤០៧.៦៦៨ | ២.០៦០.០០០ |
| ការបង់ភាគលាភ | | (៩៤.១០៨) | (៣៨៣.៤៩០) | (៥៤.៤៥២) |
| លំហូរសាច់ប្រាក់សុទ្ធបានមកពី/(ប្រើក្នុង)សកម្មភាព ហិរញ្ញវត្ថុ | | ៣០៨.៨៤១ | ១.២៥៨.៥២៨ | (១០៧.៧៥៨) |
| **កំណើន/(តំហយ)សុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់ សមមូល** | | ២៨៥.៩២៥ | ១.១៦៥.១៤៤ | (៩៨.១៣៦) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលដើមគ្រា** | | ៨៤.០៣៦ | ៣៤២.៤៤៧ | ១៨២.១៧២ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលចុងគ្រា** | | ៣៦៩.៩៦១ | ១.៥០៥.៧៩១ | ៨៤.០៣៦ |

សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមាន៖

| | កំណត់ សម្គាល់ | ២០១៩ ដុល្លារអាមេរិក | ២០១៩ ពាន់រៀល | ២០១៨ ដុល្លារអាមេរិក (កំណត់ឡើងវិញ) |
|---|---|---|---|---|
| សាច់ប្រាក់ក្នុងដៃ | ៦ | ៤០.៤៧០ | ១៦៤.៩១៥ | ៣៨.៦០៤ |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា (មិនរួមបញ្ចូលប្រាក់តម្កល់តាមច្បាប់) | ៧ | ១.៧០៦ | ៦.៩៥២ | ១.២១៦ |
| សមតុល្យនៅធនាគារផ្សេងៗ | ៨ | ៣២៧.៧៨៥ | ១.៣៣៥.៧២៤ | ៤៤.២១៦ |
| | | ៣៦៩.៩៦១ | ១.៥០៥.៧៩១ | ៨៤.០៣៦ |

**ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ**
**ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

## ១. ព័ត៌មានអំពីក្រុមហ៊ុន

ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី ហៅកាត់ថា ("ក្រុមហ៊ុន") ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ចុះបញ្ជីពាណិជ្ជកម្មលេខ ០០០០៣០០៨ នៅថ្ងៃទី២ ខែមិនា ឆ្នាំ២០១៦ ចេញដោយក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា។

ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ("NBC") នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ដើម្បីដំណើរការជាស្ថាប័នមីក្រូហិរញ្ញវត្ថុ។

នៅមុនថ្ងៃទី២ ខែមិនា ឆ្នាំ២០១៦ ក្រុមហ៊ុនធ្វើប្រត្តិការអាជីវកម្មតាមរយៈអង្គការប្រជាជាតិហិរញ្ញវត្ថុ។ នាថ្ងៃទី១ ខែមិនា ឆ្នាំ២០១៦ ដើមទុនដំបូងរបស់ក្រុមហ៊ុនបានមកពីការផ្ទេរទ្រព្យសកម្មទាំងអស់របស់អង្គការប្រជាជាតិហិរញ្ញវត្ថុ។

ការិយាល័យចុះបញ្ជីរបស់ក្រុមហ៊ុន មានទីតាំងនៅផ្ទះលេខ១៣២ ផ្លូវលេខ១៩៣ កែងផ្លូវលេខ៣៨៨ សង្កាត់ទួលស្វាយព្រៃមួយ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ("US$") ដែលជារូបិយប័ណ្ណគោលរបស់ក្រុមហ៊ុន។

របាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានអនុម័តឱ្យចេញផ្សាយដោយក្រុមប្រឹក្សាភិបាលនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០។

## ២. សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ ប្រសិទ្ធភាព ហ្វាយនែន ភីអិលស៊ី គឺផ្ដល់សេវាឥណទាន និងសេវាកម្មហិរញ្ញវត្ថុផ្សេងៗដល់គ្រួសារដែលមានចំណូលទាបនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ពុំមានការផ្លាស់ប្ដូរជាសារវន្ត សម្រាប់សកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុនក្នុងកំឡុងការិយបរិច្ឆេទនេះទេ។

## ៣. មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានរៀបចំឡើងដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់អង្គភាពធុនតូច ហៅកាត់ថា ("ស.រ.ហ.អ.ក.ស.ធ.ត.ម") ដែលបានចេញផ្សាយដោយក្រុមប្រឹក្សាគណនេយ្យជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ក្នុងការរៀបចំ និងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ។

នៅការិយបរិច្ឆេទមុន របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានរៀបចំឡើងដោយអនុលោមតាមស្តង់ដារគណនេយ្យនៃកម្ពុជា ហៅកាត់ថា ("ស.គ.ក") និងផលប៉ះពាល់នៃការអនុវត្ត "ស.រ.ហ.អ.ក.ស.ធ.ត.ម" ត្រូវបានបង្ហាញនៅកំណត់សម្គាល់លេខ៣៣ នៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

## ៤. គោលការណ៍គណនេយ្យសំខាន់ៗ

### ៤.១ មូលដ្ឋានគណនេយ្យ

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានរៀបចំឡើងដោយប្រើប្រាស់វិធីសាស្ត្រសន្មតថ្លៃដើម លើកលែង នូវអ្វីដែលបានបញ្ជាក់ក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអនុលោមតាម ស.រ.ហ.អ.ក.ស.ធ.ត.ម តម្រូវឱ្យក្រុមប្រឹក្សាភិបាលធ្វើការប៉ាន់ស្មាន និងសន្មតដែលមានផលប៉ះពាល់ដល់ចំនួនទ្រព្យសកម្មបំណុលចំណូល និងចំណាយដែលបានរាយការណ៍ព្រមទាំងការលាតត្រដាងនូវទ្រព្យសកម្មយថាហេតុនិងបំណុលយថាហេតុ។ បន្ថែមពីលើនេះក្រុមប្រឹក្សាភិបាលត្រូវបានតម្រូវឱ្យ ធ្វើការវិនិច្ឆ័យក្នុងការអនុលោមតាមគោលការណ៍គណនេយ្យទាំងនោះ។ ចំណុចទាំងឡាយណាដែលទាក់ទងដល់ការវិនិច្ឆ័យការប៉ាន់ប្រមាណ និងការសន្មតខាងលើត្រូវបានបង្ហាញនៅកំណត់សម្គាល់លេខ៥នៃរបាយការណ៍ហិរញ្ញវត្ថុ។ ទោះបីជាការប៉ាន់ស្មាន និងការសន្មតខាងលើធ្វើឡើង ដោយផ្អែកទៅលើការយល់ដឹងដ៏សុក្រឹតបំផុតរបស់ក្រុមប្រឹក្សាភិបាលទៅលើព្រឹត្តិការណ៍ និងសកម្មភាពផ្សេងៗក៏ដោយ ក៏លទ្ធផលជាក់លាក់អាចខុសគ្នាពីការប៉ាន់ស្មានទាំងនោះ។

អនុលោមទៅតាមតម្រូវការរបស់ធនាគារជាតិនៃកម្ពុជារាល់ទ្រព្យសកម្ម បំណុល និងចំណូលចំណាយដែលប្រើរូបិយប័ណ្ណបរទេស នៅក្នុងរបាយការណ៍នាដំណាច់ឆ្នាំត្រូវបំលែងទៅជារូបិយប័ណ្ណជាតិ គិតជាពាន់រៀល ("ពាន់រៀល") ដោយប្រើប្រាស់អត្រាប្តូរប្រាក់ជាផ្លូវការ ដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា នាការិយបរិច្ឆេទថ្ងៃចេញរបាយការណ៍ហិរញ្ញវត្ថុនោះដែល ១ដុល្លារអាមេរិក = ៤.០៧៥រៀល (២០១៨៖ ១ដុល្លារអាមេរិក = ៤.០១៨ រៀល)។ ការបំលែងបែបនេះមិនអាចបកស្រាយបានថាតំណាងតម្លៃលុយរៀលទាំងបច្ចុប្បន្ន ឬនាអនាគតដែលអាចបំលែងជាប្រាក់ដុល្លារអាមេរិកតាមអត្រាប្តូរប្រាក់នេះ រឺអត្រាប្តូរប្រាក់ដទៃទៀតទេ។

### ៤.២ សមតុល្យនៅធនាគារជាតិនៃកម្ពុជា

សមតុល្យនៅធនាគារជាតិនៃកម្ពុជាត្រូវបានគិតតាមថ្លៃដើមរំលោះ ដោយប្រើវិធីសាស្ត្រការប្រាក់ប្រកបដោយប្រសិទ្ធភាព។ សមតុល្យនៅធនាគារជាតិនៃកម្ពុជារួមមាន មូលនិធិបម្រុង និង ប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជាដោយអនុលោមទៅតាមច្បាប់ស្តីពីធនាគារ និងក្រុមហ៊ុនហិរញ្ញវត្ថុ ("LBFI")។ ប្រាក់តម្កល់តាមច្បាប់មិនអាចយកមក ប្រើប្រាស់សម្រាប់ប្រតិបត្តិការប្រចាំថ្ងៃបានទេ ដូច្នេះពុំត្រូវបានចាត់ទុកជាចំណែកនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូលក្នុងការរៀបចំរបាយការណ៍លំហូរសាច់ប្រាក់ឡើយ។

### ៤.៣ ទ្រព្យសម្បត្តិ និងបរិក្ខារ

ទ្រព្យសម្បត្តិ និងបរិក្ខារត្រូវបានវាស់វែងជាបឋមតាមថ្លៃដើម។ ថ្លៃដើមរួមមានចំណាយផ្ទាល់ផ្សេងៗក្នុងការទិញទ្រព្យសម្បត្តិនោះ។

ផ្នែកនីមួយៗនៃទ្រព្យសម្បត្តិ និងបរិក្ខារ ដែលមានតម្លៃដើមជាសារវន្តធៀបនឹងតម្លៃសរុបនៃទ្រព្យទាំងនោះ និងមានអាយុកាលប្រើប្រាស់ផ្សេង ត្រូវបានរំលស់ដោយឡែក។

ក្រោយការទទួលស្គាល់ដំបូង ទ្រព្យសម្បត្តិ និងបរិក្ខារត្រូវបានកត់ត្រាតាមថ្លៃដើមដករំលស់បង្គរ និងការខាតបង់បង្គរពីឱនភាពផ្សេងៗ។

រំលស់ត្រូវបានគិតដើម្បីកាត់បន្ថយថ្លៃនៃទ្រព្យសកម្ម ដោយដកតម្លៃនៃកាកសំណល់តាមអាយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់ទ្រព្យសកម្មនោះ។ អាយុកាលនៃគោលការណ៍រំលស់មានដូចខាងក្រោម៖

| | |
|---|---|
| ការកែលំអទ្រព្យដែលបានជួល | ៥ ឆ្នាំ |
| គ្រឿងសង្ហារឹម និងបរិក្ខារភ្ជាប់ | ៤ ឆ្នាំ |
| សំភារៈការិយាល័យ | ៤ ឆ្នាំ |
| គ្រឿងបរិក្ខារកុំព្យូទ័រ | ៤ ឆ្នាំ |

## ៤. គោលការណ៍គណនេយ្យសំខាន់ៗ(ត)

### ៤.៣ ទ្រព្យសម្បត្តិ និងបរិក្ខារ (ត)

នៅចុងការិយបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុ តម្លៃពិតគណនេយ្យរបស់ទ្រព្យសម្បត្តិ និងបរិក្ខារទាំងអស់ត្រូវបានវាយតម្លៃលើអំពីឱនភាពនៅពេលដែលមានព្រឹត្តិការណ៍ ឬបម្រែបម្រួលលក្ខខណ្ឌណាមួយកើតឡើង ដែលធ្វើឱ្យបាត់បង់ តម្លៃពិតគណនេយ្យនៃទ្រព្យសកម្មទាំងនោះ។ ការខាតបង់ពីឱនភាពនឹងត្រូវបានទទួលស្គាល់ នៅពេលតម្លៃពិត គណនេយ្យលើសពីតម្លៃដែលអាចប្រមូលបាន (យោងទៅកំណត់សម្គាល់លេខ ៤.៥ នៃរបាយការណ៍ហិរញ្ញវត្ថុ ស្តីពីឱនភាពនៃទ្រព្យសកម្ម មិនមែនហិរញ្ញវត្ថុ) ។

តម្លៃពិតគណនេយ្យនៃទ្រព្យសម្បត្តិ និងបរិក្ខារត្រូវបានឈប់ទទួលស្គាល់នៅពេលលក់ ឬនៅពេលមិនមានអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតបន្តទៀត។ ចំនួនខុសគ្នារវាងតម្លៃទទួលបានពីការលក់ប្រសិនបើមាន និងតម្លៃពិតគណនេយ្យត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត។

### ៤.៤ ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបីដែលអាចកំណត់អាយុកាលបាន ត្រូវបានដាក់ដោយឡែកពីគ្នាគឺត្រូវយកតម្លៃយោងចុងឆ្នាំដកនិងរំលស់បង្គរ និងឱនភាពខាតបង់បង្គរ។ ការរំលស់ត្រូវបានទទួលស្គាល់តាមរយៈវិធីសាស្ត្ររំលស់ថេរលើអាយុកាលប៉ាន់ស្មានរបស់ទ្រព្យសកម្មអរូបីនោះ។ វិធីសាស្ត្រដែលត្រូវបានកំណត់ពីអាយុកាលនិងរំលស់ ត្រូវបានពិនិត្យឡើងវិញនៅចុងការិយបរិច្ឆេទរបាយការណ៍នីមួយៗដោយមានប្រសិទ្ធិភាពក្នុងការកំណត់នៃការប្រែប្រួល ដែលត្រូវផ្អែកលើមូលដ្ឋាននាពេលអនាគត។

ទ្រព្យសកម្មអរូបីដែលមានអាយុកាលប្រើប្រាស់មិនកំណត់ ត្រូវបានដាក់ដោយឡែកពីគ្នាគឺត្រូវយកតម្លៃយោងចុងឆ្នាំ ដកនឹងឱនភាពខាតបង់បង្គរ។

### ៤.៥ ឱនភាពទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

តម្លៃពិតគណនេយ្យនៃទ្រព្យសកម្មលើកលែងទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវពិនិត្យឡើងវិញនៅរាល់ចុងការិយបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីកំណត់ថាតើមានសញ្ញានៃឱនភាពដែលអាចកើតឡើងឬទេ។ ប្រសិនបើមានសញ្ញាកើតឡើង តម្លៃដែលអាចស្តារបាននឹងត្រូវប៉ាន់ស្មាន។

ទ្រព្យសកម្មអរូបីទាំងឡាយណាដែលមានអាយុកាលមិនកំណត់ ត្រូវបានធ្វើតេស្តជារៀងរាល់ឆ្នាំដើម្បីរក ឱនភាព ឬញឹកញាប់ជាងនេះ ប្រសិនបើមានការផ្លាស់ប្តូរហេតុកាណ៍ណាមួយដែលបង្ហាញថា ទ្រព្យសកម្មអរូបីទាំងនោះមានឱនភាព។

តម្លៃដែលអាចស្តារបាននៃទ្រព្យសកម្មនីមួយៗ ត្រូវបានប៉ាន់ស្មានដោយឡែកពីគ្នា។ ករណីតម្លៃ ដែលអាចស្តារបាននៃទ្រព្យសកម្មមួយមិនអាចប៉ាន់ស្មានដោយឡែក ការប៉ាន់ស្មានលើឱនភាពនឹងធ្វើឡើង ជាក្រុម (Cash Generating Units "CGU") ដែលទ្រព្យសកម្មនោះស្ថិតនៅក្នុង។

តម្លៃដែលអាចស្តារបាននៃទ្រព្យសកម្ម ឬក្រុមទ្រព្យសកម្ម (CGU) គឺតម្លៃដែលខ្ពស់ជាងរវាងតម្លៃ ទីផ្សារដកចំណាយការលក់ និងតម្លៃនៅបន្តប្រើប្រាស់។

ក្នុងការកំណត់តម្លៃនៅបន្តប្រើប្រាស់ការប៉ាន់ស្មានលំហូរសាច់ប្រាក់ចេញ និងចូល ដែលបានមកពីការប្រើប្រាស់បន្ត និងពីការលក់ចុងក្រោយត្រូវបានធ្វើអប្បហារដោយប្រើអប្បហារអត្រាការប្រាក់មុនបង់ពន្ធ ដែលឆ្លុះបញ្ចាំងពីការវិភាគទីផ្សារបច្ចុប្បន្ននៃតម្លៃនៃពេលវេលា និងហានិភ័យដែលពាក់ព័ន្ធជាក់លាក់ទៅនឹងទ្រព្យសកម្មដែលលំហូរសាច់ប្រាក់ប៉ាន់ស្មាននាពេលអនាគតមិនបានធ្វើអប្បហារ។ ការខាតបង់ពីឱនភាព ត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍លទ្ធផលនៅពេលដែលតម្លៃពិតគណនេយ្យនៃទ្រព្យសកម្ម ឬក្រុមទ្រព្យសកម្មមានតម្លៃខ្ពស់ជាងតម្លៃដែលអាចស្តារបាន។ ការខាតបង់ពីឱនភាពទាំងអស់របស់ក្រុមទ្រព្យសកម្ម ("CGU") ត្រូវបែងចែងតាមមូលដ្ឋានសមាមាត្រតាមតម្លៃពិតគណនេយ្យរបស់ ទ្រព្យសកម្មនីមួយៗក្នុងក្រុម។ ការខាតបង់ពីឱនភាពត្រូវបានកត់ត្រាភ្លាមនៅក្នុងរបាយការណ៍ចំណេញឬខាត។

## ៤. គោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ៤.៥ ឱនភាពទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ (ត)

ការខាតបង់ពីឱនភាព អាចត្រូវបានកត់ត្រឡប់មកវិញតែក្នុងករណីដែលមានការផ្លាស់ប្តូរវិធីសាស្ត្រប៉ាន់ស្មានក្នុងការកំណត់តម្លៃដែលអាចស្តារបាននៃទ្រព្យសកម្មនោះ ចាប់តាំងពីការខាតបង់ពីឱនភាពត្រូវបានទទួលស្គាល់ចុងក្រោយតែប៉ុណ្ណោះ។

ការខាតបង់ពីឱនភាពអាចត្រូវបានកត់ត្រឡប់មកវិញត្រឹមតម្លៃពិតគណនេយ្យ នៃទ្រព្យសកម្មមិនលើសពីតម្លៃពិតគណនេយ្យ ដែលនឹងត្រូវបានកំណត់បន្ទាប់ពីដករំលស់ ប្រសិនបើមិនមានការខាតបង់ពីឱនភាពត្រូវបានទទួលស្គាល់។ ការកត់ត្រឡប់មកវិញបែបនេះត្រូវកត់ត្រាជាចំណូលភ្លាមៗ នៅក្នុងរបាយការណ៍ចំណេញ ឬខាត។

### ៤.៦ ភតិសន្យាប្រតិបត្តិការ

ភតិសន្យាត្រូវបានចាត់ថ្នាក់ជាភតិសន្យាប្រតិបត្តិការ ប្រសិនបើមិនមានការផ្ទេរជាសារវន្តនូវហានិភ័យ និងផល នៃកម្មសិទ្ធិលើទ្រព្យសម្បត្តិទេ។

ការទូទាត់ភតិសន្យា នៅក្រោមភតិសន្យាប្រតិបត្តិការត្រូវបានទទួលស្គាល់ជាចំណាយក្នុងរបាយការណ៍លទ្ធផលតាមមូលដ្ឋានថេរលើអាយុកាលនៃភតិសន្យានោះ។

### ៤.៧ ឧបករណ៍ហិរញ្ញវត្ថុ

ក្រុមហ៊ុនគួរទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ តែនៅពេលដែលតែក្រុមហ៊ុនក្លាយជាភាគីដែលជាប់កិច្ចសន្យាសំវិធានធននៃឧបករណ៍ហិរញ្ញវត្ថុ។

ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុត្រូវបានទទួលស្គាល់ដំបូងតាមតម្លៃប្រតិបត្តិការ (រួមបញ្ចូលថ្លៃដើមប្រតិបត្តិការ លើកលែងតែនៅការវាស់វែងដំបូងនៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុដែលត្រូវបានវាស់វែងនៅតម្លៃទីផ្សារជាចំណេញ ឬការខាត)។ ប្រសិនបើមិនមានការរៀបចំណាមួយដែលប៉ះពាល់ទៅលើប្រតិបត្តិការហិរញ្ញទាន។

ឥណទានអតិថិជន និងគណនីត្រូវទទួលផ្សេងៗ ត្រូវបានទទួលស្គាល់ដំបូងនៅតម្លៃប្រតិបត្តិការ និង ត្រូវបានវាស់វែងបន្ទាប់តាមរំលស់ថ្លៃដើមដោយប្រើប្រាស់វិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាពដកនឹងឱនភាព។ ឥណទានអតិថិជនត្រូវបានធ្វើឡើងតាមលក្ខខណ្ឌឥណទានធម្មតា និងគណនីពាណិជ្ជមានការប្រាក់។ នៅចុងការិយបរិច្ឆេទនីមួយៗ តម្លៃពិតគណនេយ្យនៃឥណទានអតិថិជន និងគណនីត្រូវទទួលផ្សេងៗត្រូវបានពិនិត្យឡើងវិញ ដើម្បីកំណត់ថាតើមានភស្តុតាងដែលមានចំនួនមិនអាចស្រង់យកមកវិញបានឬទេ។ ប្រសិនបើមានការខាតបង់ឱនភាពត្រូវបានទទួលស្គាល់ភ្លាមៗនៅក្នុងរបាយការណ៍ចំណេញ ឬខាត។

គណនីត្រូវបង់ផ្សេងៗ និងកម្ចីត្រូវបានទទួលស្គាល់ជាដំបូងតាមតម្លៃប្រតិបត្តិការ។ បន្ទាប់ពីការទទួលស្គាល់លើកដំបូង ពួកវាត្រូវបានវាស់វែងតាមរំលស់ថ្លៃដើមដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។ គណនីត្រូវបង់ គឺនៅលក្ខខណ្ឌឥណទានធម្មតា និងមិនមានការប្រាក់ឡើយ។

### ៤.៨ ឱនភាពទ្រព្យសកម្មហិរញ្ញវត្ថុ

ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានវាយតម្លៃនាកាលបរិច្ឆេទរាយការណ៍នីមួយៗ ដើម្បីកំណត់ថា តើមានភស្តុតាងជាយថាហេតុណាមួយថា ឱនភាពគឺជាលទ្ធផលកើតឡើងពីហេតុការណ៍មួយ ឬច្រើន ដែលជះឥទ្ធិពល អវិជ្ជមានទៅលើលំហូរសាច់ប្រាក់នាពេលអនាគតនៃទ្រព្យសកម្មនោះ។ ការខាតបង់ដែលរំពឹងពីលទ្ធផលនៃសកម្មភាពអនាគតទោះបីជាយ៉ាងណាក៏ដោយ មិនត្រូវបានទទួលស្គាល់ឡើយ។ សម្រាប់ឧបករណ៍មូលធន ការថយចុះដែលសំខាន់ ឬការថយចុះដែលពន្យានៅតម្លៃទីផ្សារដែលទាបជាងថ្លៃដើមរបស់វា គឺជាភស្តុតាងជាយថាហេតុនៃឱនភាព។

## ៤. គោលការណ៍គណនេយ្យសំខាន់ៗ(ត)

### ៤.៨ ឱនភាពទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

ក្រុមហ៊ុនពិចារណាទៅលើកត្តាទាំងឡាយ ដូចជាភវនីយភាពនៃភាពក្ស័យធន ឬឧបសគ្គហិរញ្ញវត្ថុសំខាន់ៗ រួមទាំងភាពគ្មានលទ្ធភាពសងបំណុល ឬក៏ការពន្យាពេលសងបំណុលដើម្បី កំណត់ថាតើកត្តាទាំងនោះជាភស្តុតាង ដែលបញ្ជាក់ថាមានឱនភាពលើកម្ចីបានកើតឡើង។ កត្តាផ្សេងទៀតដែលអាចជាភស្តុតាងនៃឱនភាព រួមមានការកែទម្រង់នៃកម្ចី ការបាត់បង់តម្លៃនៃទីផ្សាររបស់ទ្រព្យធានា និងបម្រែបម្រួលអវិជ្ជមានដែលមានឡើងនៅក្នុងបរិបទសេដ្ឋកិច្ច។

បើមានភស្តុតាងបែបនេះកើតឡើង តម្លៃនៃការខាតបង់ត្រូវបានគណនាដោយកំណត់តម្លៃ ខុសគ្នារវាងតម្លៃពិតគណនេយ្យនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់ នាអនាគតដែលបានធ្វើអប្បហារតាមអត្រាការប្រាក់ប្រសិទ្ធផល ដើមនៃទ្រព្យសកម្មហិរញ្ញវត្ថុនោះ។ អត្រាការប្រាក់ប្រសិទ្ធផលត្រូវបានកាត់បន្ថយតាមរយៈការប្រើគណនីសំវិធានធនលើឱនភាពហើយចំនួនឱនភាពនោះត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល។

ប្រាក់កម្ចីដែលមិនមានសារៈសំខាន់ជាលក្ខណៈដោយឡែកហើយត្រូវបានគេវាយតម្លៃជា ដាច់ដោយពីគ្នាដោយមិនមានភស្តុតាង នៃការខាតបង់លើឱនភាពនៃតម្លៃត្រូវបានដាក់ជាក្រុមរួមគ្នាសម្រាប់ការវាយតម្លៃពីឱនភាពសមូហភាព។ ប្រាក់កម្ចីទាំងនេះត្រូវបានដាក់ជាក្រុមក្នុងលក្ខណៈហានិភ័យឥណទាន ប្រហាក់ប្រហែលសម្រាប់ការវាយតម្លៃសមូហភាពដែលទិន្នន័យពីប្រាក់កម្ចីបុរេហិរញ្ញប្បទាននិងផលប័ត្រហិរញ្ញប្បទាន (ដូចជាគុណភាពឥណទានកម្រិតបំណុល ការប្រើឥណទានប្រាក់កម្ចី អនុបាតទ្រព្យបញ្ចាំជាដើម) និងការប្រមូលផ្តុំហានិភ័យ (ដូចជាលក្ខណៈនៃក្រុមបុគ្គលផ្សេងគ្នា) ត្រូវបានគេយកមកពិចារណា។

នៅការិយបរិច្ឆេទបន្ទាប់ ប្រសិនបើតម្លៃខាតបង់ពីឱនភាពថយចុះហើយទាក់ទងទៅនឹងព្រឹត្តិការណ៍ណាមួយដែលកើតឡើងក្រោយការខាតបង់ត្រូវបានទទួលស្គាល់ ហើយការខាតបង់ដែលបានទទួលស្គាល់ពីមុន ត្រូវបានកត់ត្រឡប់មកវិញត្រឹមពេលដែលតម្លៃពិតគណនេយ្យនៃទ្រព្យសកម្មមិនលើសពីតម្លៃដែលបានរំលស់នៅថ្ងៃដែលកត់ត្រឡប់មកវិញ។ ចំនួនដែលបានកត់ត្រឡប់មកវិញត្រូវទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាត។

### ៤.៩ ទុនបម្រុងកាតព្វកិច្ច

ទុនបម្រុងកាតព្វកិច្ច ត្រូវបានរក្សាទុកបន្ថែមទៅលើសំវិធានធនសម្រាប់ឥណទានជាប់សង្ស័យ ដែលត្រូវបានវាយតម្លៃ និងទទួលស្គាល់ដោយអនុលោមទៅតាម ស.រ.ហ.អ.ក.ស.ធ.ត.ម និងដែលត្រូវបានផ្ទេរពីចំណេញរក្សាទុកដោយអនុលោមទៅតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជាលេខ ធ៧-០១៧-៣៤៤ ប្រ.ក ចុះថ្ងៃទី១ ខែធ្នូឆ្នាំ២០១៧ និងសារាចរណែនាំលេខ ធ៧-០១៨-០០១ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៨។

គោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា តម្រូវអោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងឡាយ ធ្វើចំណាត់ថ្នាក់ឥណទានរបស់ខ្លួនជាប្រាំថ្នាក់ ហើយត្រូវប្រាកដថាក្រុមហ៊ុនរបស់ខ្លួនបានបំពេញកាតព្វកិច្ចសំវិធានធនអប្បបរមាដូចខាងក្រោម៖

| **ចំណាត់ថ្នាក់** | **ចំនួនថ្ងៃដែលផុតកំណត់** | **សំវិធានធន** |
|---|---|---|
| ឥណទានរយៈពេលខ្លី (តិចជាង១ឆ្នាំ) | | |
| **ទូទៅ** | | |
| ធម្មតា | ពី ០ថ្ងៃ ទៅ ១៤ថ្ងៃ | ១% |
| **ជាក់លាក់** | | |
| ឃ្លាំមើល | ពី ១៥ថ្ងៃ ទៅ ៣០ថ្ងៃ | ៣% |
| ក្រោមស្តង់ដារ | ពី ៣១ថ្ងៃ ទៅ ៦០ថ្ងៃ | ២០% |
| សង្ស័យ | ពី ៦១ថ្ងៃ ទៅ៩០ថ្ងៃ | ៥០% |
| បាត់បង់ | ៩១ថ្ងៃ ឬ ច្រើនជាង | ១០០% |

## ៤. គោលការណ៍គណនេយ្យសំខាន់ៗ(ត)

### ៤.៩ ទុនបម្រុងកាតព្វកិច្ច(ត)

| **ចំណាត់ថ្នាក់** | **ចំនួនថ្ងៃដែលផុតកំណត់** | **សំវិធានធន** |
|---|---|---|
| ឥណទានរយៈពេលវែង (លើសពី១ឆ្នាំ) | | |
| **ទូទៅ** | | |
| ធម្មតា | ពី ០ថ្ងៃ ទៅ ២៩ថ្ងៃ | ១% |
| **ជាក់លាក់** | | |
| ឃ្លាំមើល | ពី ៣០ថ្ងៃ ទៅ ៨៩ថ្ងៃ | ៣% |
| ក្រោមស្តង់ដារ | ពី ៩០ថ្ងៃ ទៅ ១៧៩ថ្ងៃ | ២០% |
| សង្ស័យ | ពី ១៨០ថ្ងៃ ទៅ ៣៥៩ថ្ងៃ | ៥០% |
| បាត់បង់ | ៣៦០ថ្ងៃ ឬ ច្រើនជាង | ១០០% |

ដោយអនុលោមទៅតាម មាត្រា ៧៣ នៃប្រកាសលេខ ធ៧-០១៧-៣៤៤ ប្រ.ក ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៧ ក្រុមហ៊ុនត្រូវប្រៀបធៀប សំវិធានធនដែលគណនាតាមគោលការណ៍ខាងលើ និងសំវិធានធនរបស់ក្រុមហ៊ុនដែលបានកត់ត្រាតាម ស.រ.ហ.អ.ក.ស.ធ.ត.ម៖

ក. ប្រសិនបើសំវិធានធនតាមច្បាប់តិចជាង ក្រុមហ៊ុនត្រូវកត់ត្រាសំវិធានធនដោយអនុលោមទៅតាម ស.រ.ហ.អ.ក.ស.ធ.ត.ម និង

ខ. ប្រសិនបើសំវិធានធនតាមច្បាប់ច្រើនជាង ក្រុមហ៊ុនត្រូវកត់ត្រាសំវិធានធនដោយអនុលោមទៅតាម ស.រ.ហ.អ.ក.ស.ធ.ត.ម និងត្រូវផ្ទេរភាពខុសគ្នាពីចំណេញរក្សាទុក មកទុនបម្រុងតាមច្បាប់នៅក្នុងមូលធន។

### ៤.១០ ពន្ធលើប្រាក់ចំណេញ

ពន្ធលើប្រាក់ចំណេញរួមមានពន្ធលើប្រាក់ចំណេញជាប់ពន្ធទាំងអស់។ បន្ទុកពន្ធនៅក្នុងរបាយការណ៍លទ្ធផលរួមមាន ពន្ធចរន្ត និងពន្ធពន្យា។

(ក) ពន្ធចរន្ត

បន្ទុកពន្ធចរន្តត្រូវបានកំណត់ដោយអនុលោមតាមច្បាប់ស្តីពីសារពើពន្ធក្នុងព្រះរាជាណាចក្រកម្ពុជា ដែលរួមបញ្ចូលទាំងមូលដ្ឋានពន្ធយោងតាមប្រាក់ចំណេញជាប់ពន្ធ។

(ខ) ពន្ធពន្យា

ទ្រព្យសកម្មពន្ធពន្យា ឬបំណុលពន្ធពន្យាត្រូវបានទទួលស្គាល់សម្រាប់ពន្ធដែលអាចស្តារបានឬបំណុលនាពេលអនាគតដែលជាលទ្ធផលនៃប្រតិបត្តិការ ឬព្រឹត្តិការណ៍កន្លងមក។ ពន្ធពន្យាកើតឡើងពីភាពខុសគ្នា (ត្រូវបានគេហៅភាពខុសគ្នាបណ្តោះអាសន្ន) រវាងតម្លៃពិតគណនេយ្យនៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរួមបញ្ចូលគ្នា និងមូលដ្ឋានពន្ធរបស់វា។ មូលដ្ឋានពន្ធនៃទ្រព្យសកម្មត្រូវបាន កំណត់តាមរយៈលទ្ធផលនៃការលក់ទ្រព្យសកម្ម។

## ៤. គោលការណ៍គណនេយ្យសំខាន់ៗ(ត)

### ៤.១០ ពន្ធលើប្រាក់ចំណេញ (ត)

(ខ) ពន្ធពន្យា (ត)

បំណុលពន្ធពន្យាត្រូវបានទទួលស្គាល់ដោយមានការរំពឹងថា ភាពខុសគ្នាបណ្តោះអាសន្ននឹងធ្វើឱ្យមានកំណើននៃប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត លើកលែងតែមានការទាក់ទងនឹងទ្រព្យសកម្មសប្បុរស។ ទ្រព្យសកម្មពន្ធពន្យាត្រូវបានទទួលស្គាល់សម្រាប់រាល់ភាពខុសគ្នាបណ្តោះអាសន្នដែលត្រូវបានរំពឹងថានឹងធ្វើឱ្យមាន តំហាយប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតហើយនិងកំហាតពន្ធដែលមិនបានប្រើប្រាស់។

ទ្រព្យសកម្មពន្ធពន្យា ត្រូវបានវាស់វែងគិតជាតម្លៃអតិបរមាដែលប្រហែលនឹងកើតឡើងច្រើនជាងមិនកើតឡើងថានឹងស្តារបានដោយផ្អែកលើប្រាក់ចំណេញជាប់ពន្ធបច្ចុប្បន្ន ឬប្រាក់ចំណេញជាប់ពន្ធសន្មត នាពេលអនាគត។ តម្លៃពិតគណនេយ្យសុទ្ធរបស់ទ្រព្យសកម្មពន្ធពន្យាត្រូវបានត្រួតពិនិត្យឡើងវិញ នៅរាល់ចុងការិយបរិច្ឆេទ និងត្រូវបានធ្វើនិយ័តកម្មដើម្បីឆ្លើយតបនឹងការវាយតម្លៃបច្ចុប្បន្នលើប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត។ និយ័តកម្មនានា ត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញឬខាត ប្រសិនបើនិយ័តកម្មនោះមិនជាប់ទាក់ទងក្នុងរបាយការណ៍លទ្ធផល។

ពន្ធពន្យាត្រូវបានគណនាតាមអត្រាពន្ធដែលគិតថានឹង អាចអនុវត្តលើប្រាក់ចំណេញជាប់ពន្ធ ឬការខាតបង់ពន្ធ នៅក្នុងកំឡុងការិយបរិច្ឆេទដែលគណៈគ្រប់គ្រងរំពឹងថាទ្រព្យសកម្មពន្ធពន្យាត្រូវបានទទួលស្គាល់ ឬបំណុលពន្ធពន្យាត្រូវបានទូទាត់តាមមូលដ្ឋាននៃអត្រាពន្ធដែលបានអនុម័ត ឬក៏នឹងត្រូវបានអនុម័តត្រឹមចុងការិយបរិច្ឆេទ។

### ៤.១១ សំវិធានធន

សំវិធានធនត្រូវបានទទួលស្គាល់នៅពេលដែលមានកាតព្វកិច្ចផ្លូវច្បាប់ ឬកាតព្វកិច្ចដែលបង្កើតឡើងនាពេលបច្ចុប្បន្ន ដែលជាលទ្ធផលនៃព្រឹត្តិការណ៍ពីអតីតកាលទំនងជាអាចតម្រូវឱ្យមានការចំណាយធនធាន ដើម្បីទូទាត់កាតព្វកិច្ចនោះ ហើយចំនួនទឹកប្រាក់អាចត្រូវបានប៉ាន់ស្មានគួរឱ្យជឿជាក់បាន។

នៅពេលដែលផលប៉ះពាល់នៃតម្លៃសាច់ប្រាក់គិតតាមពេលវេលាមានលក្ខណៈជាសារវន្ត ចំនួនសំវិធានធនត្រូវធ្វើអប្បហារមកជាតម្លៃបច្ចុប្បន្នតាមអត្រាមុនគិតពន្ធ ដែលអត្រានេះឆ្លុះបញ្ចាំងពីការវាយតម្លៃទីផ្សារបច្ចុប្បន្ននៃតម្លៃសាច់ប្រាក់គិតតាមពេលវេលា និងហានិភ័យជាក់លាក់ផ្សេងៗនៃកាតព្វកិច្ចនោះ។

សំវិធានធនត្រូវបានធ្វើការត្រួតពិនិត្យឡើងវិញ នៅរៀងរាល់ចុងការិយបរិច្ឆេទនៃរបាយការណ៍ និងត្រូវបានកែតម្រូវដើម្បីឆ្លុះបញ្ចាំងពីការប៉ាន់ស្មានបច្ចុប្បន្នដែលត្រឹមត្រូវបំផុត។ សំវិធានធននឹងត្រូវធ្វើការកត់ត្រលប់មកវិញប្រសិនបើមិនទំនងថានឹងមានការចំណាយធនធានដើម្បីទូទាត់កាតព្វកិច្ចនោះទេ។

សំវិធានធនមិនបានទទួលស្គាល់ការខាតបង់នាពេលអនាគត។ ប្រសិនបើក្រុមហ៊ុនមានកិច្ចសន្យាដែលចំណូលនឹងទទួលបានតិចជាងចំណាយដែលកើតឡើង នោះកាតព្វកិច្ចបច្ចុប្បន្ននៅក្រោមកិច្ចសន្យានោះត្រូវបានទទួលស្គាល់ និងវាស់វែងជាសំវិធានធន។

### ៤.១២ ការទទួលស្គាល់ចំណូលការប្រាក់

(ក) ចំណូលការប្រាក់

ចំណូលការប្រាក់ ត្រូវបានទទួលស្គាល់វិធីសាស្រ្តការប្រាក់មានប្រសិទ្ធភាព។

ចំពោះគណនីឥណទានដែលបានចំណាត់ថ្នាក់ជាគណនីមិនមានសកម្មភាពសងត្រឡប់ ការកត់ត្រាចំណូលពីការប្រាក់ត្រូវបានផ្អាករហូតដល់មានសំណងជាសាច់ប្រាក់វិញ។ គណនីឥណទានអតិថិជនត្រូវបានចំណាត់ថ្នាក់ជាឥណទានមិនមានសកម្មភាពសងត្រឡប់ក្នុងករណីសំណងមានការយឺតយ៉ាវចាប់ពី ៣០ថ្ងៃឡើងទៅ។

## ៤. គោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ៤.១២ ការទទួលស្គាល់ចំណូលការប្រាក់ (ត)

(ខ) ចំណូលប្រតិបត្តិការផ្សេងៗ

ក្រុមហ៊ុនទទួលបាន និងការបង់ផ្ដាច់មុនកាល កំណត់ ឬការបង់យឺតយ៉ាវ និងការរៀបចំកិច្ចសន្យាឥណទានរបស់អតិថិជន។ ចំណូលទាំងនេះត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍លទ្ធផល តាមមូលដ្ឋានបង្គរ។

### ៤.១៣ អត្ថប្រយោជន៍និយោជិក

(ក) អត្ថប្រយោជន៍និយោជិករយៈពេលខ្លី

ប្រាក់ឈ្នួល ប្រាក់បៀវត្ស វិភាគទានសន្តិសុខសង្គម ប្រាក់បង់ការឈប់សម្រាកប្រចាំឆ្នាំប្រាក់បង់ ការឈប់សម្រាកពេលឈឺអត្ថប្រយោជន៍បន្ថែម និងអត្ថប្រយោជន៍មិនមែនសាច់ប្រាក់ គឺត្រូវបានវាស់វែងដោយផ្អែកលើមូលដ្ឋានមិនគិតអប្បហារ និងត្រូវបានទទួលស្គាល់ជាចំណាយ នៅពេលដែលនិយោជិកទាំងនោះបានបំពេញការងារឱ្យក្រុមហ៊ុន។

ប្រាក់សំណងបង្គររយៈពេលខ្លីរួមមាន ប្រាក់បង់ការឈប់សម្រាកប្រចាំឆ្នាំ ដែលត្រូវបានកំណត់ដោយបានទទួលស្គាល់ជាចំណាយនៅពេលនិយោជិកទាំងនោះ បានបម្រើការងារដោយបង្កើនសិទ្ធិទទួលបានរបស់ពួកគាត់នៅថ្ងៃអនាគត។ អវត្តមានរយៈពេលខ្លីមិនបង្គរសម្រាប់ទូទាត់ ដូចជាការឈប់សម្រាកឈឺ ត្រូវបានទទួលស្គាល់នៅពេលដែលអវត្តមាននោះកើតឡើង ហើយប្រសិនបើការឈប់សម្រាកនោះមិនត្រូវបានប្រើប្រាស់ទាំងស្រុងនៅក្នុងការិយបរិច្ឆេទនិយោជិកនឹងមិនត្រូវបានទូទាត់ជូនជា សាច់ប្រាក់នៅចុងការិយបរិច្ឆេទ ឬនៅពេលដែលលាឈប់ពីក្រុមហ៊ុនឡើយ។

អត្ថប្រយោជន៍បន្ថែមគឺត្រូវបានទទួលស្គាល់ជាចំណាយនៅពេលដែលមានកាតព្វកិច្ចផ្លូវច្បាប់ ឬកាតព្វកិច្ចដែលបង្កើតឡើងនាពេលបច្ចុប្បន្នតម្រូវឱ្យមានការបង់ប្រាក់ ដែលជាលទ្ធផលកើតចេញពី ព្រឹត្តិការណ៍កន្លងមក និងនៅពេលដែលមានការប៉ាន់ស្មានជាក់លាក់ អាចត្រូវបានធ្វើឡើងពីចំនួននៃកាតព្វកិច្ច។

(ខ) អត្ថប្រយោជន៍ពីការបញ្ឈប់ការងារ

អត្ថប្រយោជន៍ពីការបញ្ឈប់ការងារ គឺជាសំណងដែលត្រូវបង់ជូននិយោជិតដោយការបញ្ឈប់ពីការងារមុនពេលថ្ងៃចូលនិវត្តន៍ ឬការស្ម័គ្រចិត្តរបស់និយោជិត ដើម្បីទទួលយកអត្ថប្រយោជន៍ទាំងនោះជាថ្នូរនឹងការបញ្ឈប់ពីការងារដោយការស្ម័គ្រចិត្ត។ អត្ថប្រយោជន៍ទាំងនោះត្រូវបានទទួលស្គាល់ជាបំណុល និងចំណាយនៅពេលដែលក្រុមហ៊ុនមានគម្រោងបញ្ឈប់ការងារនយោជិតជាផ្លូវការច្បាស់លាស់ ដោយមិនមានលក្ខខណ្ឌណាដែលគម្រោងនេះត្រូវដកចេញ។ ក្នុងករណីការបញ្ឈប់ដោយស្ម័គ្រចិត្ត ដោយនិយោជិតលើសពីតម្រូវការអត្ថប្រយោជន៍នោះ ត្រូវបានគណនាផ្អែកទៅលើចំនួននិយោជិតដែលរំពឹងថានឹងទទួលការស្នើសុំនេះ។

នៅពេលដែលអត្ថប្រយោជន៍ពីការបញ្ឈប់ការងារហួសការជំពាក់កំណត់លើសពី ១២ខែ បន្ទាប់ពីចុងនៃការិយបរិច្ឆេទ អត្ថប្រយោជន៍នោះត្រូវបានធ្វើអប្បហារទៅជាតម្លៃបច្ចុប្បន្នដោយផ្អែកលើលទ្ធផលទីផ្សារនៅចុងការិយបរិច្ឆេទ។

## ៤. គោលការណ៍គណនេយ្យសំខាន់ៗ(ត)

### ៤.១៤ រូបិយប័ណ្ណបរទេស

(ក) រូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញ

គណនីទាំងអស់ដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានវាស់វែងដោយ ប្រើប្រាស់រូបិយប័ណ្ណនៃបរិយាកាសសេដ្ឋកិច្ចចម្បង ដែលក្រុមហ៊ុនធ្វើប្រតិបត្តិការហៅកាត់ថា ("រូបិយប័ណ្ណ គោល")។ រូបិយប័ណ្ណជាតិរបស់ព្រះរាជាណាចក្រកម្ពុជាគឺ ប្រាក់រៀលខ្មែរ ("រៀល") ប៉ុន្តែក្រុមហ៊ុនធ្វើប្រតិបត្តិការអាជីវកម្ម និងរក្សានូវកំណត់ត្រាគណនេយ្យចម្បងជាប្រាក់ដុល្លារអាមេរិក។ ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនកំណត់យកប្រាក់ដុល្លារអាមេរិកជារូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញដោយសារវាឆ្លុះបញ្ចាំងពីធាតុសេដ្ឋកិច្ចនៃព្រឹត្តិការណ៍ និងកាលៈទេសៈរបស់ក្រុមហ៊ុន។

(ខ) ប្រតិបត្តិការ និងសមតុល្យរូបិយប័ណ្ណបរទេស

ប្រតិបត្តិការជារូបិយប័ណ្ណបរទេស ត្រូវបានប្តូរទៅជារូបិយប័ណ្ណគោល របស់ក្រុមហ៊ុន ដោយប្រើប្រាស់អត្រាប្តូរប្រាក់នៅថ្ងៃប្រតិបត្តិការនោះ។ ទ្រព្យសកម្ម និងបំណុលជារូបិយប័ណ្ណបរទេស នាថ្ងៃចុងក្រោយនៃការិយបរិច្ឆេទត្រូវបានប្តូរទៅជារូបិយប័ណ្ណមុខងាររបស់ក្រុមហ៊ុន ដោយប្រើអត្រាប្តូរប្រាក់នាថ្ងៃនោះ។ រាល់ភាពខុសគ្នាដែលបណ្តាលមកពីរបាយការណ៍រូបិយប័ណ្ណបរទេស និងពីបម្លាស់ប្តូររូបិយប័ណ្ណបរទេសនៃទ្រព្យសកម្ម និងបំណុលត្រូវដាក់បញ្ចូលទៅក្នុងរបាយការណ៍ចំណេញឬខាតសម្រាប់ការិយបរិច្ឆេទនោះតែម្តង។ ទ្រព្យសកម្ម និងបំណុលមិនមែនជារូបិយវត្ថុ ដែលកត់ត្រាដំបូងជា រូបិយប័ណ្ណបរទេស ហើយយោងជាតម្លៃដើមត្រូវបានកែសម្រួលដោយប្រើអត្រាដើមនៅថ្ងៃទិញ ហើយចំពោះទ្រព្យសកម្មនិងបំណុលមិនមែនជារូបិយវត្ថុ ដែលយោងជាតម្លៃទីផ្សារត្រូវបានប្រែសម្រួលដោយប្រើអត្រាប្តូរប្រាក់ដែលកើតឡើងនៅពេលដែលតម្លៃនៃទ្រព្យសកម្ម និងបំណុលទាំងនោះត្រូវបានកំណត់ក្នុងគោលបំណងសម្រាប់បង្ហាញ។

### ៤.១៥ បន្ទុកលើប្រាក់កម្ចី

បន្ទុកលើប្រាក់កម្ចី ត្រូវបានកត់ត្រាក្នុងរបាយការណ៍ចំណេញ ឬខាត នៅការិយបរិច្ឆេទដែលប្រតិបត្តិការនោះកើតឡើង។

## ៥. ការប៉ាន់ស្មាន និង ការវិនិច្ឆ័យគណនេយ្យសំខាន់ៗ

### ៥.១. ការផ្លាស់ប្តូរការប៉ាន់ស្មាន

ការប៉ាន់ស្មាន ត្រូវបានធ្វើការវាយតម្លៃជាបន្តបន្ទាប់ និងយោងតាមបទពិសោធព្រមទាំងកត្តាផ្សេងៗទៀតរួមមានការរំពឹងទុកពីព្រឹត្តិការណ៍នាពេលអនាគត ដែលត្រូវបានគេជឿជាក់ថាមានភាពសមស្របក្នុងកាលៈទេសៈមួយ។

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល ពុំមានការផ្លាស់ប្តូរជាសារវន្តនូវការប៉ាន់ស្មាននៅក្នុងកំឡុង និងចុងការិយបរិច្ឆេទនោះទេ។

### ៥.២. ការវិនិច្ឆ័យសំខាន់ៗដែលធ្វើឡើងក្នុងការអនុវត្តគោលការណ៍គណនេយ្យ

មិនមានការវិនិច្ឆ័យសំខាន់ៗ ត្រូវបានធ្វើឡើងដោយថ្នាក់ដឹកនាំក្នុងដំណើរការនៃការអនុវត្តគោលការណ៍គណនេយ្យរបស់ក្រុមហ៊ុន ដែលមានផលប៉ះពាល់ជាសារវន្ត ទៅលើចំនួនដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុឡើយ ក្រៅពីចំនួនទាំងឡាយណាដែលទាក់ទងនឹងការប៉ាន់ស្មានដូចមានខាងក្រោម។

## ៥. ការប៉ាន់ស្មាន និង ការវិនិច្ឆ័យគណនេយ្យសំខាន់ៗ (ត)

### ៥.៣ ប្រភពសំខាន់ៗនូវភាពមិនពិតប្រាកដនៃការប៉ាន់ស្មាន

ខាងក្រោមនេះ គឺជាការសន្និដ្ឋានសំខាន់ៗទាក់ទងទៅនឹងពេលអនាគត និងប្រភពសំខាន់ៗ ដទៃទៀតនៃភាពមិនពិតប្រាកដនៃការប៉ាន់ស្មានក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ដែលមានហានិភ័យជាសារវន្ត ដែលបណ្តាលឱ្យមាននិយ័តកម្មជាសារវន្ត ទៅលើតម្លៃពិតគណនេយ្យរបស់ទ្រព្យសកម្ម និងបំណុល នៅក្នុងការិយបរិច្ឆេទបន្ទាប់។

(ក) រំលស់នៃទ្រព្យសម្បត្តិ និងបរិក្ខារ

ថ្លៃដើមនៃទ្រព្យសម្បត្តិ និងបរិក្ខារ និងត្រូវបានរំលស់ ដោយប្រើប្រាស់វិធីសាស្ត្ររំលស់ថេរ ផ្អែកលើអាយុកាលប្រើប្រាស់របស់ទ្រព្យទាំងនោះ។ ថ្នាក់ដឹកនាំបានធ្វើការប៉ាន់ស្មាននូវអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្មទាំងនេះ ដោយផ្អែកលើបទពិសោធន៍ ការប្រើប្រាស់រំពឹងទុក ការខូចខាត និង ភាពហួសសម័យនៃបច្ចេកទេសដែលកើតឡើងពីការផ្លាស់ប្តូរនៅក្នុងតម្រូវការទីផ្សារ ឬសេវាកម្មដែលផ្តល់ដោយទ្រព្យសកម្មទាំងនោះ។ ការផ្លាស់ប្តូរនូវកត្តាទាំងនេះអាចនឹងមានផលប៉ះពាល់ដល់អាយុកាលប្រើប្រាស់សេដ្ឋកិច្ច និងតម្លៃកាកសំណល់នៃទ្រព្យសកម្ម។ ដូច្នេះ រំលស់នាពេលអនាគតអាចនឹងត្រូវបានកែប្រែ។

(ខ) ឱនភាពលើឥណទានអតិថិជន

ក្រុមហ៊ុន ធ្វើសំវិធានធនលើឥណទានអតិថិជន ដោយផ្អែកទៅលើការវិនិច្ឆ័យលើភាពដែលអាចប្រមូលមកវិញបានរបស់ទឹកប្រាក់ដែលត្រូវទទួល។ ឱនភាពត្រូវបានធ្វើឡើងលើទឹកប្រាក់ត្រូវទទួល នៅពេលដែលការផ្លាស់ប្តូរបរិយាកាសណាមួយដែលអាចជាកត្តាជំរុញ ធ្វើអោយតម្លៃពិតគណនេយ្យអាចនឹងស្រង់មកវិញមិនបាន។ គណៈគ្រប់គ្រងបានធ្វើការវិភាគស៊ីជម្រៅលើបំណុល ដែលមានប្រវត្តិពិបាកទារ ការផ្តោតអារម្មណ៍របស់អតិថិជន ភាពគួរឱ្យជឿជាក់របស់អតិថិជន និន្នាការ សេដ្ឋកិច្ចបច្ចុប្បន្ន និងការផ្លាស់ប្តូរលក្ខខណ្ឌនៃការបង់ប្រាក់ នៅពេលដែលធ្វើការវិនិច្ឆ័យមួយ ដើម្បីវាយតម្លៃភាពគ្រប់គ្រាន់នៃឱនភាពរបស់ឥណទានអតិថិជន។នៅពេលដែលមានភាពខុសគ្នារវាងការរំពឹងទុក និងការប៉ាន់ស្មានដំបូងភាពខុសគ្នានោះនឹងប៉ះពាល់ដល់តម្លៃពិតគណនេយ្យនៃឥណទានអតិថិជន។

(គ) ការចំណាយលើប្រាក់ពន្ធ

ការវិនិច្ឆ័យសំខាន់ៗ ត្រូវបានរួមបញ្ចូលក្នុងការកំណត់នូវសំវិធានធនរបស់ក្រុមហ៊ុន សម្រាប់ពន្ធលើប្រាក់ចំណេញ។ ក្រុមហ៊ុននឹងទទួលស្គាល់បំណុលសម្រាប់រាល់ចំណាយលើពន្ធដែលរំពឹងទុកផ្អែកទៅលើ ការប៉ាន់ស្មានតាមរយៈការបកស្រាយបទប្បញ្ញត្តិពន្ធផ្សេងៗដោយថ្នាក់ដឹកនាំ ថាតើពន្ធទាំងនោះត្រូវបង់ឬទេ។ នៅពេលដែលលទ្ធផលពន្ធខុសគ្នាពីការប៉ាន់ស្មានដែលត្រូវបានទទួលស្គាល់ពីមុន ភាពខុសគ្នាទាំងនោះនឹងមានផលប៉ះពាល់ដល់សំវិធានធនពន្ធក្នុងការិយបរិច្ឆេទ ដែលការកំណត់នោះត្រូវបានធ្វើឡើង។

## ៦. សាច់ប្រាក់ក្នុងដៃ

| | ២០១៩ | | ២០១៨ |
|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| សាច់ប្រាក់ក្នុងដៃ | ៤០.៤៧០ | ១៦៤.៩១៥ | ៣៨.៦០៤ |

## ៧. សមតុល្យនៅធនាគារជាតិនៃកម្ពុជា

| | ២០១៩ | | ២០១៨ |
|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ប្រាក់តម្កល់តាមច្បាប់ | ១៤៥.៧៨៨ | ៥៩៤.០៨៦ | ១៤៥.៧៨៨ |
| គណនីចរន្ត | ១.៧០៦ | ៦.៩៥២ | ១.២១៦ |
| | ១៤៧.៤៩៤ | ៦០១.០៣៨ | ១៤៧.០០៤ |

ប្រាក់តម្កល់តាមច្បាប់

អនុលោមតាមប្រកាសលេខ ធ៧-០០-០០៦ប្រ.ក. ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០ និងប្រកាសលេខ ធ៧-០៦-២០៩ប្រ.ក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦ ស្តីពីការផ្តល់អាជ្ញាប័ណ្ណដល់ក្រុមហ៊ុនមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនត្រូវរក្សានូវប្រាក់តម្កល់លើដើមទុនចំនួន៥%នៃដើមទុនចុះបញ្ជី។ ប្រាក់តម្កល់នេះនឹងត្រូវបង្វិលឱ្យ ក្រុមហ៊ុនវិញនៅពេលដែលក្រុមហ៊ុនស្ម័គ្រចិត្តបញ្ចប់អាជីវកម្មរបស់ខ្លួន។

## ៨. សមតុល្យនៅធនាគារផ្សេងៗ

| | ២០១៩ | | ២០១៨ |
|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ធនាគារអេស៊ីលីដា ភីអិលស៊ី | ៣១៩.២២៧ | ១.៣០០.៨៥០ | ៤៣.២៨៥ |
| ធនាគារហ្វីលីព ភីអិលស៊ី | ៤.៧៧១ | ១៩.៤៤២ | ៩១៩ |
| ធនាគារព្រីនស៍ ភីអិលស៊ី | ៣.៧៦៥ | ១៥.៣៤២ | - |
| ធនាគារអភិវឌ្ឍន៍ជនបទ | ២២ | ៩០ | ១២ |
| | ៣២៧.៧៨៥ | ១.៣៣៥.៧២៤ | ៤៤.២១៦ |

## ៩. ឥណទានអតិថិជន

| | ២០១៩ | | ២០១៨ |
|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ឥណទានទៅអតិថិជន | ៤.២២៧.៤៦៦ | ១៧.២២៦.៩២៤ | ៤.១៨១.៨០៧ |
| សំវិធានធនសម្រាប់ឥណទានជាប់សង្ស័យ | (១.២៨៦) | (៥.២៤០) | (៣.៣៤៨) |
| | ៤.២២៦.១៨០ | ១៧.២២១.៦៨៤ | ៤.១៧៨.៤៥៩ |

## ៩. ឥណទានអតិថិជន (ត)

### (ក) សំវិធានធនសម្រាប់ឥណទានជាប់សង្ស័យ

| | ២០១៩ ដុល្លារអាមេរិក | ២០១៩ ពាន់រៀល | ២០១៨ ដុល្លារអាមេរិក |
|---|---|---|---|
| សំវិធានធនដើមគ្រា | ៣.៣៤៨ | ១៣.៦៤៣ | ៣.៤៩០ |
| សំវិធានធនក្នុងការិយបរិច្ឆេទ | ៣០.៨៩៩ | ១២៥.៨១៣ | - |
| ត្រលប់មកវិញក្នុងការិយបរិច្ឆេទ | - | - | (១៤២) |
| ការជម្រះចេញពីបញ្ជី | (៣២.៩៦១) | (១៣៤.៣១៦) | - |
| សំវិធានធនចុងគ្រា | ១.២៨៦ | ៥.២៤០ | ៣.៣៤៨ |

### (ខ) វិភាគតាមកាលកំណត់

| | ២០១៩ ដុល្លារអាមេរិក | ២០១៩ ពាន់រៀល | ២០១៨ ដុល្លារអាមេរិក |
|---|---|---|---|
| តិចជាង ១ឆ្នាំ | ៤.៣១៤ | ១៧.៥៨០ | ១២.២០៨ |
| ពី ១ឆ្នាំ ទៅ ៥ឆ្នាំ | ៤.២២៣.១៥២ | ១៧.២០៩.៣៤៤ | ៤.១៦៩.៥៩៩ |
| | ៤.២២៧.៤៦៦ | ១៧.២២៦.៩២៤ | ៤.១៨១.៨០៧ |

### (គ) វិភាគតាមប្រភេទរូបិយប័ណ្ណ

| | ២០១៩ ដុល្លារអាមេរិក | ២០១៩ ពាន់រៀល | ២០១៨ ដុល្លារអាមេរិក |
|---|---|---|---|
| ដុល្លារអាមេរិក | ៣.៥៨៥.៩៦៤ | ១៤.៦១២.៨០៣ | ៣.៩០០.១៥៩ |
| ខ្មែររៀល | ៦៤១.៥០២ | ២.៦១៤.១២១ | ២៨១.៦៤៨ |
| | ៤.២២៧.៤៦៦ | ១៧.២២៦.៩២៤ | ៤.១៨១.៨០៧ |

### (ឃ) វិភាគតាមសេដ្ឋកិច្ច

| | ២០១៩ ដុល្លារអាមេរិក | ២០១៩ ពាន់រៀល | ២០១៨ ដុល្លារអាមេរិក |
|---|---|---|---|
| គ្រួសារ | ៣.០១២.៤២២ | ១២.២៧៥.៦១៩ | ១.៩៦៦.៧១១ |
| កសិកម្ម | ១១៧.៣៩៦ | ៤៧៨.៣៨៩ | ២៤៤.០០០ |
| មធ្យោបាយដឹកជញ្ជូន | ៣៧.៦៣៧ | ១៥៣.៣៧១ | ៧៨.៩៨៧ |
| ជំនួញ និងពាណិជ្ជកម្ម | ៣០៦.១៤០ | ១.២៤៧.៥២១ | ៦៨៨.៥៥៥ |
| សេវាកម្ម | ១៩.៤៣៤ | ៧៩.១៩៤ | ១៨.៣៣៣ |
| សំណង់ | ៦៥៥.៥៩២ | ២.៦៧១.៥៣៧ | ១.០៦៧.៤៧៤ |
| ផ្សេងៗទៀត | ៧៨.៨៤៥ | ៣២១.២៩៣ | ១១៧.៧៤៧ |
| | ៤.២២៧.៤៦៦ | ១៧.២២៦.៩២៤ | ៤.១៨១.៨០៧ |

## ៩. ឥណទានអតិថិជន (ត)

### (ង) វិភាគតាមសម្ព័ន្ធភាគី

| | ២០១៩ | | ២០១៨ |
|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ឥណទានទៅអតិថិជនខាងក្រៅ | ៤.១៥៩.១៦៦ | ១៦.៩៤៨.៦០១ | ៤.០៦៤.០៦០ |
| ឥណទានទៅបុគ្គលិក | ៦៨.៣០០ | ២៧៨.៣២៣ | ១១៧.៧៤៧ |
| | ៤.២២៧.៤៦៦ | ១៧.២២៦.៩២៤ | ៤.១៨១.៨០៧ |

### (ច) វិភាគតាមការធានាលើឥណទានដំណើរការ និងមិនដំណើរការ

| | ២០១៩ | | ២០១៨ |
|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| **ឥណទានស្តង់ដារ៖** | | | |
| មានវត្ថុធានា | ៤.០២៦.៦៨០ | ១៦.៤០៨.៧២១ | ៣.៨៤១.០៤២ |
| គ្មានវត្ថុធានា | ១៤០.៥០០ | ៥៧២.៥៣៨ | ២៥៤.៥៧៤ |
| **ឥណទានថ្នាក់ឃ្លាំមើល៖** | | | |
| មានវត្ថុធានា | ១០.២០២ | ៤១.៥៧៣ | ១១.៥៦៩ |
| គ្មានវត្ថុធានា | ៣.០៨១ | ១២.៥៥៥ | ១១.០៧២ |
| **ឥណទានថ្នាក់ក្រោមស្តង់ដារ៖** | | | |
| មានវត្ថុធានា | ៩.៥២៩ | ៣៨.៨៣១ | ៨.០០៧ |
| គ្មានវត្ថុធានា | - | - | ១០.៩២៦ |
| **ឥណទានជាប់សង្ស័យ៖** | | | |
| មានវត្ថុធានា | ២៦.២៥៦ | ១០៦.៩៩៣ | ៥.៧៨០ |
| **ឥណទានបាត់បង់៖** | | | |
| មានវត្ថុធានា | ១១.២១៨ | ៤៥.៧១៣ | ៣២.២០៧ |
| គ្មានវត្ថុធានា | - | - | ៦.៦៣០ |
| | ៤.២២៧.៤៦៦ | ១៧.២២៦.៩២៤ | ៤.១៨១.៨០៧ |

## ៩. ឥណទានអតិថិជន(ត)

### (ឆ) វិភាគតាមហានិភ័យ

| | ២០១៩ ដុល្លារអាមេរិក | ២០១៩ ពាន់រៀល | ២០១៨ ដុល្លារអាមេរិក |
|---|---|---|---|
| ហានិភ័យធំៗ | - | - | - |
| មិនមែនហានិភ័យធំៗ | ៤.២២៧.៤៦៦ | ១៧.២២៦.៩២៤ | ៤.១៨១.៨០៧ |
| | ៤.២២៧.៤៦៦ | ១៧.២២៦.៩២៤ | ៤.១៨១.៨០៧ |

ហានិភ័យធំៗ ត្រូវបានផ្តល់និយមន័យនៅក្នុងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជាថាជាសមតុល្យសរុបនៃឥណទាន និងបុរេប្រទានដែលផ្តល់ដល់អតិថិជនម្នាក់លើសពី ១០%ផ្ទាល់សុទ្ធរបស់មូលធនរបស់ក្រុមហ៊ុន។ ហានិភ័យនេះសំដៅលើចំនួនប្រាក់ខ្ពស់បំផុតនៃឥណទានដែលនៅសល់ និងទាយជ្ជទាន និងឥណទានដែលនៅសល់ ឬទាយជ្ជទានដែលបានអនុម័ត។

## ១០. គណនីត្រូវទទួលផ្សេងៗ

| | ២០១៩ ដុល្លារអាមេរិក | ២០១៩ ពាន់រៀល | ២០១៨ ដុល្លារអាមេរិក |
|---|---|---|---|
| **គណនីត្រូវទទួលផ្សេងៗ** | | | |
| ការប្រាក់ត្រូវទទួល | ៤៥.១០៦ | ១៨៣.៨០៧ | ៤៦.២៨៧ |
| ការទទួលផ្សេងៗ | ១៣.៣៧៨ | ៥៤.៥១៥ | ១៩.៤៩២ |
| | ៥៨.៤៨៤ | ២៣៨.៣២២ | ៦៥.៧៧៩ |
| **ប្រាក់កក់ និងការបង់មុន** | | | |
| ប្រាក់កក់ | ៩០.០៣៧ | ៣៦៦.៩០១ | ៩១.៨៣៧ |
| ការបង់មុន | ១៣.៨១២ | ៥៦.២៨៤ | ១៩.៦១៩ |
| | ១០៣.៨៤៩ | ៤២៣.១៨៥ | ១១១.៤៥៦ |
| | ១៦២.៣៣៣ | ៦៦១.៥០៧ | ១៧៧.២៣៥ |

## ១១. ទ្រព្យសម្បត្តិ និងបរិក្ខារ

| | ការជួសជុល កែលំអ ដុល្លារអាមេរិក | គ្រឿងសង្ហារឹម និង គ្រឿងបំពាក់ ដុល្លារអាមេរិក | សម្ភារការិយាល័យ ដុល្លារអាមេរិក | គ្រឿងបរិក្ខារកុំព្យូទ័រ ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|---|---|
| *ថ្លៃដើម* | | | | | |
| **សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០១៨** | ១៣២.៦៩៣ | ៦.២៧៤ | ៤១.៤៥០ | ៣១.៤៣៧ | ២១១.៨៥៤ |
| ការទិញបន្ថែម | ២៩៦ | - | ១.៩២០ | ៤.៤៧២ | ៦.៦៨៨ |
| ការជម្រះចេញពីបញ្ជី | - | (១.២៩៥) | (១.១២០) | (១.០៤៦) | (៣.៤៦១) |
| **សមតុល្យនា ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨** | ១៣២.៩៨៩ | ៤.៩៧៩ | ៤២.២៥០ | ៣៤.៨៦៣ | ២១៥.០៨១ |
| ការទិញបន្ថែម | - | - | ២.៤០០ | - | ២.៤០០ |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩** | ១៣២.៩៨៩ | ៤.៩៧៩ | ៤៤.៦៥០ | ៣៤.៨៦៣ | ២១៧.៤៨១ |
| *រំលស់បង្គរ* | | | | | |
| **សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០១៨** | ១៨.៨៤៦ | ៤.៩៣៤ | ១៨.១២៥ | ១៦.៤៥៥ | ៥៨.៣៦០ |
| រំលស់ក្នុងគ្រា | ២៦.៥៤៦ | ៧៦២ | ៨.៣៤០ | ៧.០៤១ | ៤២.៦៨៩ |
| ការជម្រះចេញពីបញ្ជី | - | (១.២៤៩) | (១.១១៨) | (៩៤៩) | (៣.៣១៦) |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨** | ៤៥.៣៩២ | ៤.៤៤៧ | ២៥.៣៤៧ | ២២.៥៤៧ | ៩៧.៧៣៣ |
| រំលស់ក្នុងគ្រា | ២៦.៤៦១ | ៣៧១ | ៧.៦៦៣ | ៥.០៥៦ | ៣៩.៥៥១ |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩** | ៧១.៨៥៣ | ៤.៨១៨ | ៣៣.០១០ | ២៧.៦០៣ | ១៣៧.២៨៤ |

## ១១. ទ្រព្យសម្បត្តិ និងបរិក្ខារ(ត)

| | ការជួសជុល កែលំអ ដុល្លារអាមេរិក | គ្រឿងសង្ហារឹម និង គ្រឿងបំពាក់ ដុល្លារអាមេរិក | សម្ភារការិយាល័យ ដុល្លារអាមេរិក | គ្រឿងបរិក្ខារកុំព្យូទ័រ ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|---|---|
| *តម្លៃពិតគណនេយ្យ* | | | | | |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩** | **៦១.១៣៦** | **១៦១** | **១១.៦៤០** | **៧.២៦០** | **៨០.១៩៧** |
| *(គិតជាពាន់រៀល)* | *២៤៩.១២៩* | *៦៥៦* | *៤៧.៤៣៤* | *២៩.៥៨៤* | *៣២៦.៨០៣* |
| សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | ៨៧.៥៩៧ | ៥៣២ | ១៦.៩០៣ | ១២.៣១៦ | ១១៧.៣៤៨ |

## ១២. ទ្រព្យសកម្មអរូបី

| | កម្មវិធីកុំព្យូទ័រ<br>ដុល្លារអាមេរិក |
|---|---|
| *ថ្លៃដើម* | |
| **សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០១៨** | ១០.២៥០ |
| ការទិញបន្ថែម | - |
| **សមតុល្យនា ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨** | ១០.២៥០ |
| ការទិញបន្ថែម | ៣៨.៩១៣ |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩** | ៤៩.១៦៣ |
| *រំលស់បង្គរ* | |
| **សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០១៨** | ៦.៥៨២ |
| រំលស់ក្នុងឆ្នាំ | ១.៩៩០ |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨** | ៨.៥៧២ |
| រំលស់ក្នុងឆ្នាំ | ៧.៧៩៤ |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩** | ១៦.៣៦៦ |
| *តម្លៃពិតគណនេយ្យ* | |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩** | **៣២.៧៩៧** |
| *(គិតជាពាន់រៀល)* | *១៣៣.៦៤៨* |
| សមតុល្យនា ថ្ងៃទី៣១ ខែធ្នូឆ្នាំ២០១៨ | ១.៦៧៨ |

## ១៣. ពន្ធពន្យា

ធាតុនិងបម្រែបម្រួលនៃពន្ធពន្យាទ្រព្យសកម្មមានដូចខាងក្រោម៖

| | គិតត្រឹមថ្ងៃទី ១ មករា ២០១៩ ដុល្លារអាមេរិក | ការទទួលស្គាល់ ចំណេញ/ខាត (កំណត់សម្គាល់២៦) ដុល្លារអាមេរិក | ការទទួលស្គាល់ជា ចំណូលផ្សេងទៀត ដុល្លារអាមេរិក | គិតត្រឹមថ្ងៃទី ៣១ ធ្នូ ២០១៩ ដុល្លារអាមេរិក |
|---|---|---|---|---|
| ទ្រព្យសម្បត្តិ និងបរិក្ខារ | ៧៤៥ | ៣.២០៦ | - | ៣.៩៥១ |
| សំវិធានធន | ១៧.៦៥២ | ១.៣៧៤ | - | ១៩.០២៦ |
| | ១៨.៣៩៧ | ៤.៥៨០ | - | ២២.៩៧៧ |
| *(គិតជាពាន់រៀល)* | *៧៤.៩៦៧* | *១៨.៦៦៤* | - | *៩៣.៦៣១* |

| | គិតត្រឹមថ្ងៃទី ១ មករា ២០១៨ ដុល្លារអាមេរិក | ការទទួលស្គាល់ ចំណេញ/ខាត (កំណត់សម្គាល់២៦) ដុល្លារអាមេរិក | ការទទួលស្គាល់ជា ចំណូលផ្សេងទៀត ដុល្លារអាមេរិក | គិតត្រឹមថ្ងៃទី ៣១ ធ្នូ ២០១៨ ដុល្លារអាមេរិក |
|---|---|---|---|---|
| ទ្រព្យសម្បត្តិ និងបរិក្ខារ | (១.១៨៨) | ១.៩៣៣ | - | ៧៤៥ |
| សំវិធានធន | ៨.១០៤ | ៩.៥៤៨ | - | ១៧.៦៥២ |
| | ៦.៩១៦ | ១១.៤៨១ | - | ១៨.៣៩៧ |

## ១៤. កម្ចី

| | ២០១៩ ដុល្លារអាមេរិក | ២០១៩ ពាន់រៀល | ២០១៨ ដុល្លារអាមេរិក |
|---|---|---|---|
| **ភាគីពាក់ព័ន្ធ** | | | |
| ឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី | ២៦០.០០០ | ១.០៥៩.៥០០ | ១៦០.០០០ |
| Mengly J. Quach Education | - | - | ៧០០.០០០ |
| | ២៦០.០០០ | ១.០៥៩.៥០០ | ៨៦០.០០០ |
| **ភាគីមិនពាក់ព័ន្ធ** | | | |
| ឯកត្តជន | ១៧០.០០០ | ៦៩២.៧៥០ | ១៥០.០០០ |
| ធនាគារហ្វីលីព ភីអិលស៊ី | ៦៣៨.០៣៧ | ២.៦០០.០០១ | - |
| ធនាគារព្រីនស៍ ភីអិលស៊ី | ៤០៨.៩៩៨ | ១.៦៦៦.៦៦៧ | - |
| ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម | - | - | ៦៤.០៨៦ |
| | ១.២១៧.០៣៥ | ៤.៩៥៩.៤១៨ | ២១៤.០៨៦ |
| | ១.៤៧៧.០៣៥ | ៦.០១៨.៩១៨ | ១.០៧៤.០៨៦ |

## ១៥. គណនីត្រូវបង់ផ្សេងៗ

| | ២០១៩ | | ២០១៨ |
|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ការប្រាក់ដែលត្រូវបង់ | ១៣.៦៨៤ | ៥៥.៧៦២ | ៩.៧៤៣ |
| បង្គរ | ១៣.៤១២ | ៥៤.៦៥៤ | ៤២.៦៩០ |
| ចំណូលមិនទាន់ទទួលស្គាល់ | ៥០.៤៥១ | ២០៥.៥៨៨ | ៥៣.១៨៤ |
| បំណុលផ្សេងៗ | ៨.៩៣៣ | ៣៦.៤០៣ | ២.៨០៣ |
| | ៨៦.៤៨០ | ៣៥២.៤០៧ | ១០៨.៤២០ |

## ១៦. ដើមទុន

| | ២០១៩ | | ២០១៨ | |
|---|---|---|---|---|
| | ចំនួន | ដុល្លារអាមេរិក | ចំនួន | ដុល្លារអាមេរិក |
| ភាគហ៊ុនធម្មតា ១ ដុល្លារ អាមេរិកក្នុងមួយភាគហ៊ុន បានចុះបញ្ជី | ២.៩១៥.៧៦៦ | ២.៩១៥.៧៦៦ | ២.៩១៥.៧៦៦ | ២.៩១៥.៧៦៦ |
| បានចុះបញ្ជី និងបោះផ្សាយ ៖ នាថ្ងៃទី១ ខែមករា/ថ្ងៃទី៣១ ខែធ្នូ | ២.៩១៥.៧៦៦ | ២.៩១៥.៧៦៦ | ២.៩១៥.៧៦៦ | ២.៩១៥.៧៦៦ |
| *(គិតជាពាន់រៀល)* | | *១១.៨៨១.៧៤៦* | | |

ម្ចាស់ភាគហ៊ុននៃក្រុមហ៊ុនមានសិទ្ធិទទួលបានភាគលាភ នៅពេលដែលប្រកាសដោយក្រុមហ៊ុនហើយមានសិទ្ធិបោះឆ្នោតមួយក្នុងមួយភាគហ៊ុនធម្មតានៅក្នុងការប្រជុំរបស់ក្រុមហ៊ុន។ ភាគហ៊ុនធម្មតាទាំងអស់មានចំណាត់ថ្នាក់ pari passu ទាក់ទងទៅនឹងទ្រព្យសកម្មដែលនៅសល់របស់ក្រុមហ៊ុន។

## ១៧. ដើមទុនផ្សេងៗ

| | ២០១៩ | | ២០១៨ |
|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ឧកញ៉ា វេជ្ជបណ្ឌិត គួយ ម៉េងលី | ១៧៩.១៥១ | ៧៣០.០៤០ | ១៧៩.១៥១ |
| ក្រុមហ៊ុនភីអេហ្វអេសអេ ភីអិលស៊ី | ១០.៨៤៩ | ៤៤.២១០ | ១០.៨៤៩ |
| | ១៩០.០០០ | ៧៧៤.២៥០ | ១៩០.០០០ |

ដើមទុនផ្សេងៗតំណាងឱ្យដើមទុនផ្ទេរពីក្រុមហ៊ុន ដែលមិនទាន់បានសុំការអនុម័តពីធនាគារជាតិនៃកម្ពុជា និងក្រសួងពាណិជ្ជកម្ម ដើម្បីបំលែងជាដើមទុនស្របច្បាប់។

## ១៨. ទុនបម្រុង

| | ២០១៩ | | ២០១៨ |
|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ទុនបម្រុងកាតព្វកិច្ច | ៦៧.០៣៧ | ២៣៧.១៧៦ | ៨៣.៨០១ |
| ទុនបម្រុងផ្សេងៗ | ១៧.៤៣១ | ៧១.០៣១ | ១២.៨៧៦ |
| | ៨៤.៤៦៨ | ៣៤៤.២០៧ | ៩៦.៦៧៧ |

ទុនបម្រុងកាតព្វកិច្ច

ទុនបម្រុងតាមច្បាប់ ត្រូវបានរក្សាទុកបន្ថែមទៅលើសំវិធានធនសម្រាប់ឥណទានជាប់សង្ស័យ ដែលត្រូវបានវាយតម្លៃ និងទទួលស្គាល់ដោយអនុលោមទៅតាម ស.រ.ហ.អ.ក.ស.ធ.ត.ម និងដែលត្រូវបានផ្ទេរពីចំណេញរក្សាទុក ដោយអនុលោមទៅតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជាលេខ ធ៧-០១៧-៣៤៤ ប្រ.ក ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៧ និងសារាចរណែនាំលេខ ធ៧-០១៨-០០១ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៨។

ទុនបម្រុងផ្សេងៗ:

ទុនបម្រុងតាមច្បាប់

ដោយអនុលោមតាមអនុស្សរណៈ និងលក្ខន្តិកៈ ក្រុមហ៊ុនត្រូវបង្វែរប្រាក់ចំណេញសុទ្ធចំនួន ៥% នៃប្រាក់ចំណេញសុទ្ធក្នុងការិយបរិច្ឆេទចេញពីប្រាក់ចំណេញរក្សាទុក ក្នុងទុនបម្រុង។

ទុនបម្រុងសម្រាប់វិភាគទានជួយអភិវឌ្ឍន៍សង្គម

ដោយអនុលោមតាមអនុស្សារណៈ និងលក្ខន្តិកៈ ក្រុមហ៊ុនត្រូវបង្វែរប្រាក់ចំណេញសុទ្ធចំនួន ១% នៃចំណេញសុទ្ធក្នុងការិយបរិច្ឆេទ (ប្រាក់ចំណេញសុទ្ធបន្ទាប់ពីបានកាត់ទុនបម្រុងតាមច្បាប់ ៥%) ចេញពីប្រាក់ចំណេញរក្សាទុកចូលក្នុងទុនបម្រុងសម្រាប់វិភាគទានជួយ។

## ១៩. ចំណូលការប្រាក់

| | ២០១៩ | | ២០១៨ |
|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ឥណទានទៅអតិថិជន | ៩២៥.៧៥៧ | ៣.៧៧២.៤៥៩ | ៨៨៨.៤៩១ |
| ប្រាក់បញ្ញើនៅធនាគារ | ៦.២៦២ | ២៥.៥១៨ | ១.០១៨ |
| | ៩៣២.០១៩ | ៣.៧៩៧.៩៧៧ | ៨៨៩.៥០៩ |

## ២០. ចំណាយការប្រាក់

| | ២០១៩ | | ២០១៨ |
|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| កម្ចីពីភាគីពាក់ព័ន្ធ | ៣០.៥០៥ | ១២៤.៣០៧ | ៧៩.៨៩៩ |
| កម្ចីផ្សេងៗ | ១០៥.៩១៨ | ៤៣១.៦១៧ | ៣០.១៩៧ |
| | ១៣៦.៤២៣ | ៥៥៥.៩២៤ | ១១០.០៩៦ |

## ២១. សំវិធានធនសម្រាប់ឥណទាន

| | ២០១៩ | | ២០១៨ |
|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| សំវិធានធនសម្រាប់ឥណទានជាប់សង្ស័យ | ៣០.៨៩៩ | ១២៥.៩១៣ | - |

## ២២. ចំណូលប្រតិបត្តិការផ្សេងៗ

| | ២០១៩ | | ២០១៨ |
|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| កម្រៃ និងចំណូលកម្រៃជើងសារ | ៩.០២២ | ៣៦.៧៦៥ | ៣.៤៤៨ |
| ចំណូលផ្សេងៗ | ៦.១៥៤ | ២៥.០៧៧ | ១១.៤១២ |
| | ១៥.១៧៦ | ៦១.៨៤២ | ១៤.៨៦០ |

## ២៣. ចំណាយប្រាក់បៀវត្ស

| | ២០១៩ | | ២០១៨ |
|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ប្រាក់បៀវត្ស និងប្រាក់ឈ្នួល | ៣១៩.៧៩០ | ១.៣០៣.១៤៤ | ៣០៨.៨៦៣ |
| ចំណាយអត្ថប្រយោជន៍ផ្សេងៗ | ១១៧.៣៥៤ | ៤៧៨.២១៨ | ១០៣.៥០០ |
| | ៤៣៧.១៤៤ | ១.៧៨១.៣៦២ | ៤១២.៣៦៣ |

## ២៤. ចំណាយរំលស់

| | ២០១៩ | | ២០១៨ |
|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| រំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ | ៣៩.៥៥១ | ១៦១.១៧០ | ៤២.៦៨៩ |
| រំលស់ទ្រព្យសកម្មអរូបី | ៧.៧៩៤ | ៣១.៧៦១ | ១.៩៩០ |
| | ៤៧.៣៤៥ | ១៩២.៩៣១ | ៤៤.៦៧៩ |

## ២៥. ចំណាយទូទៅ និងរដ្ឋបាល

| | ២០១៩ | | ២០១៨ |
|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ចំណាយលើអាហារ និងការកម្សាន្ត | ៦៦ | ២៦៩ | ៣៦៥ |
| ចំណាយផ្នែកទំនាក់ទំនង | ៧.២៦៥ | ២៩.៦០៥ | ៨.២៩៥ |
| ចំណាយលើសមាជិកភាព | ៣.៩៧៤ | ១៦.១៩៤ | ៣.៧១៧ |
| កម្រៃ និងចំណាយកម្រៃជើងសារលើកម្ចី | ៣.៦៩៥ | ១៥.០៥៧ | ៣.៥៦៦ |
| ចំណាយលើអាជ្ញាប័ណ្ណ | ៨.២៧៧ | ៣៣.៧២៩ | ៨.២៣៣ |
| ចំណាយលើយានយន្ត | ៧.១៦៤ | ២៩.១៩៣ | ២៦.៩៦៧ |
| ចំណាយលើការបោះពុម្ព និងសម្ភារៈការិយាល័យ | ៤.៧៨៤ | ១៩.៤៩៥ | ៣.៣៣៩ |
| ចំណាយលើសេវាវិជ្ជាជីវៈ និងពន្ធផ្សេងៗ | ៥១.៦២៩ | ២១០.៣៨៨ | ១៩.៤២១ |
| ចំណាយការជួល | ៨៩.៦៨៨ | ៣៦៥.៤៧៩ | ៨១.៣៣៣ |
| ចំណាយលើការជួសជុល និងថែទាំ | ១.៤៣២ | ៥.៨៣៥ | ៣.៥៧៤ |
| ចំណាយលើសេវាសន្តិសុខ | ៥.៦១៦ | ២២.៨៨៥ | ៥.៣៩០ |
| ចំណាយលើការធ្វើដំណើរ | ៣.០៣២ | ១២.៣៥៥ | ២.៧៣១ |
| ចំណាយលើទឹកភ្លើង | ១២.៩១៦ | ៥២.៦៣៣ | ១២.១០៣ |
| ចំណាយផ្សេងៗ | ២៩.៥០៨ | ១២០.២៤៥ | ២២.២៥៤ |
| | ២២៩.០៤៦ | ៩៣៣.៣៦២ | ២០១.២៨៨ |

## ២៦. ចំណាយពន្ធ

| | ២០១៩ | | ២០១៨ |
|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ចំណាយពន្ធលើប្រាក់ចំណេញ៖ | | | |
| ក្នុងការិយបរិច្ឆេទបច្ចុប្បន្ន | ២២.១៧៧ | ៩០.៣៧២ | ៦៨.៣២៨ |
| លើសសំវិធានធនក្នុងឆ្នាំមុន | (២៧.៨១៥) | (១១៣.៣៤៦) | - |
| | (៥.៦៣៨) | (២២.៩៧៤) | ៦៨.៣២៨ |
| ចំណាយលើពន្ធពន្យា (កំណត់សម្គាល់១៣)៖ | | | |
| ភាពខុសគ្នាបណ្តោះអាសន្ន | (៤.៥៨០) | (១៨.៦៦៤) | (១១.៤៨១) |
| សរុប | (១០.២១៨) | (៤១.៦៣៨) | ៥៦.៨៤៧ |

ផ្អែកលើច្បាប់ស្តីពីសារពើពន្ធរបស់ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនមានកាតព្វកិច្ចក្នុងការបង់ពន្ធលើប្រាក់ចំណេញក្នុងអត្រា ២០% (២០១៨៖ ២០%) នៃប្រាក់ចំណេញជាប់ពន្ធ ឬពន្ធអប្បបរមា១% (២០១៨៖ ១%) នៃប្រាក់ចំណូលសរុប ប្រសិនបើមួយណាមានតម្លៃច្រើនជាង។

## ២៦. ចំណាយពន្ធ (ត)

តួលេខសម្រាប់ផ្ទុផ្ទងរវាងចំណាយពន្ធ នឹងផលគុណនៃចំណេញគណនេយ្យ និងអត្រាពន្ធដាររបស់ក្រុមហ៊ុន មានដូចខាងក្រោម៖

| | ២០១៩ | | ២០១៨ |
|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ចំណេញមុនដកចំណាយពន្ធ | ៦៦.៣៣៨ | ២៧០.៣២៧ | ១៣៥.៩៤៣ |
| ពន្ធគណនាតាមអត្រាពន្ធស្របច្បាប់២០% (២០១៨៖ ២០%) | ១៣.២៦៨ | ៥៤.០៦៦ | ២៧.១៨៩ |
| ឥទ្ធិពលពន្ធដារទៅលើ៖ | | | |
| ចំណាយដែលមិនអាចកាត់កងពន្ធ | ៤.៣២៩ | ១៧.៦៤២ | ២៩.៦៥៨ |
| | ១៧.៥៩៧ | ៧១.៧០៨ | ៥៦.៨៤៧ |
| សំវិធានធនលើសក្នុងការិយបរិច្ឆេទមុន | | | |
| - ពន្ធលើប្រាក់ចំនូល | (២៧.៨១៥) | (១១៣.៣៤៦) | - |
| | (១០.២១៨) | (៤១.៦៣៨) | ៥៦.៨៤៧ |

## ២៧. ភាគលាភ

| | ២០១៩ | | ២០១៨ | |
|---|---|---|---|---|
| | ភាគលាភក្នុងមួយភាគហ៊ុន | តម្លៃក្នុងមួយភាគលាភ | ភាគលាភក្នុងមួយភាគហ៊ុន | តម្លៃក្នុងមួយភាគលាភ |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| ភាគលាភលើកដំបូង និងចុងក្រោយបានបង់ | | | | |
| - សម្រាប់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ | 0,0១៦ | ៤៦.៨៩០ | - | - |
| - សម្រាប់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | 0,0១៦ | ៤៧.២១៨ | - | - |
| | | ៩៤.១០៨ | | - |

## ២៨. ការសន្យាភតិសន្យាប្រតិបត្តិការ

<u>ក្រុមហ៊ុនជាភតិក:</u>

ក្រុមហ៊ុនបានចុះកិច្ចសន្យា ជាភតិសន្យាប្រតិបត្តិការដែលមិនអាចលុបចោលបានសម្រាប់ការជួលការិយាល័យ ដែលជាលទ្ធផលនៃកិច្ចសន្យាជួលនាពេលអនាគត ដែលនឹងអនុលោមតាមលក្ខខណ្ឌមួយចំនួននៅក្នុងកិច្ចសន្យា ហើយនឹងអាចត្រូវកែតំរូវតាមអត្រាទីផ្សារប្រចាំឆ្នាំ។ នៅចុងការិយបរិច្ឆេទនេះ ក្រុមហ៊ុននៅមានការសន្យាយោងតាមភតិសន្យាប្រតិបត្តិការដែលមិនអាចលុបចោលបាន និងត្រូវដល់ពេលបង់នៅកាលបរិច្ឆេទដូចខាងក្រោម៖

| | ២០១៩ | | ២០១៨ |
|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| មិនលើសពី ១ឆ្នាំ | ១៧២.៦៥៣ | ៧០៣.៥៦១ | ១៧៩.៩៨៧ |
| លើស ១ឆ្នាំ និងមិនលើសពី ៥ឆ្នាំ | ៥០៩.២៨០ | ២.០៧៥.៣១៦ | ៥៣២.៦៧០ |
| លើសពី ៥ឆ្នាំ | ៨៩.៩១១ | ៣៦៦.៣៨៧ | ១០៨.០០០ |
| | ៧៧១.៨៤៤ | ៣.១៤៥.២៦៤ | ៨២០.៦៥៧ |

## ២៩. ប្រតិបត្តិការភាគីពាក់ព័ន្ធ

(ក) ក្រុមហ៊ុនមានប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធក្នុងកំឡុងការិយបរិច្ឆេទដូចខាងក្រោម៖

| | ២០១៩ | | ២០១៨ |
|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| <u>ភាគហ៊ុនិក</u> | | | |
| ឧកញ៉ា វេជ្ជបណ្ឌិត គួច ម៉េងលី | | | |
| កម្ចីបានផ្តល់ | ២៦០.០០០ | ១.០៥៩.៥០០ | ៨១០.០០០ |
| ការទូទាត់សង | ១៦០.០០០ | ៦៥២.០០០ | ១.០៥០.០០០ |
| ចំណាយការប្រាក់ | ៩.២១៩ | ៣៧.៥៦៦ | ២៦.៤៦៩ |
| <u>ក្រោមការគ្រប់គ្រងតែមួយ</u> | | | |
| Mengly J. Quach Education | | | |
| កម្ចីបានផ្តល់ | - | - | ១.១០០.០០០ |
| ការទូទាត់សង | ៧០០.០០០ | ២.៨៥២.៥០០ | ៦០០.០០០ |
| ចំណាយការប្រាក់ | ២១.២៨៦ | ៨៦.៧៤១ | ៥៣.៤៣០ |

តុល្យការជាមួយភាគីពាក់ព័ន្ធនៅចុងកំឡុងការិយបរិច្ឆេទនៃរបាយការណ៍នេះ ត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់លេខ ១៤ នៃរបាយការណ៍ហិរញ្ញវត្ថុ។

ប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធដែលបង្ហាញខាងលើត្រូវបាន ធ្វើឡើងតាមលក្ខខណ្ឌពាណិជ្ជកម្មធម្មតា។

## ២៩. ប្រតិបត្តិការភាគីពាក់ព័ន្ធ (ត)

(ខ) អត្ថប្រយោជន៍របស់គណៈគ្រប់គ្រង

| | ២០១៩ | | ២០១៨ |
|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| គណៈគ្រប់គ្រង | ១១២.៩៦៣ | ៤៦០.៣២៤ | ១៥៨.៨១៩ |

## ៣០. គោលដៅ និងគោលការណ៍នៃការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ

គោលការណ៍នៃការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គឺដើម្បីធ្វើឱ្យប្រសើរបំផុតនូវការបង្កើនតម្លៃដល់ម្ចាស់ភាគហ៊ុនខណៈកាត់បន្ថយជាអប្បបរមានូវផលប៉ះពាល់អវិជ្ជមាន ដែលកើតឡើងដោយសារការប្រែប្រួលនៃទីផ្សារហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលមានតួនាទីកំណត់គោលដៅ និងគោលការណ៍នៃការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ក្រុមហ៊ុន។ បន្ទាប់មកក្រុមប្រឹក្សាភិបាលបង្កើតនូវគោលការណ៍លំអិតដូចជាគោលការណ៍ទាក់ទងនឹងឋានានុក្រម ក្នុងការត្រួតពិនិត្យការកំណត់អត្តសញ្ញាណ និងការវាស់វែងហានិភ័យ និងកម្រិតហានិភ័យដែលអនុលោមតាមគោលដៅ និងគោលការណ៍ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល។

ព័ត៌មានទៅលើការគ្រប់គ្រងនៃការប្រឈមមុខនឹងហានិភ័យ ត្រូវបានបញ្ជាក់លម្អិតដូចខាងក្រោម៖

(១) ហានិភ័យឥណទាន

ក្រុមហ៊ុនសន្មតហានិភ័យលើឥណទានដែលត្រូវបានកំណត់ថាជាហានិភ័យ ក្នុងករណីដែលអ្នកសុំខ្ចីមិនអាចសងបំណុលទាំងស្រុងនៅថ្ងៃដល់កាលកំណត់។ ក្រុមហ៊ុនធ្វើការចាត់ថ្នាក់កម្រិតហានិភ័យលើឥណទានដែលខ្លួនអាចរ៉ាប់រងដោយដាក់កម្រិតហានិភ័យជាទឹកប្រាក់ដែលអាចផ្តល់ទៅអ្នកសុំខ្ចីណាមួយ ក្រុមអ្នកសុំខ្ចីណាមួយ និងលើតំបន់ភូមិសាស្ត្រ និងលើផ្នែកសេដ្ឋកិច្ច។ នីតិវិធីដើម្បីដាក់កម្រិតលើហានិភ័យ ការត្រួតពិនិត្យ ការប្រើប្រាស់ និងការគ្រប់គ្រងត្រូវបានធ្វើឡើងដោយផ្អែកទៅលើបទបញ្ជាផ្ទៃក្នុង។ ហានិភ័យទាំងនេះត្រូវបានតាមដានត្រួតពិនិត្យជា ទៀងទាត់។

ហានិភ័យលើឥណទាន ត្រូវបានចាត់ចែងតាមរយៈការវិភាគទៀងទាត់លើសមត្ថភាពសងរបស់អ្នកសុំខ្ចី និងអ្នកដែលរំពឹងថាជាអ្នកសុំខ្ចី ដើម្បីសងការប្រាក់ និងប្រាក់ដើម និងតាមរយៈការពិនិត្យឡើងវិញនូវកម្រិតនៃប្រាក់ឱ្យខ្ចីក្នុងករណីសមស្រប។ ហានិភ័យលើឥណទានក៏ត្រូវបានចាត់ចែងជាផ្នែកដោយទទួលនូវវត្ថុបញ្ចាំ និងការធានាជាលក្ខណៈក្រុមហ៊ុន ឬបុគ្គល ព្រមទាំងផ្តល់នូវឥណទានបាត់បង់។

ក. ការគ្រប់គ្រងកម្រិតហានិភ័យ និងគោលការណ៍កាត់បន្ថយហានិភ័យ

ក្រុមហ៊ុនធ្វើប្រតិបត្តិការ និងផ្តល់ឥណទានទៅឱ្យឯកត្តជន ឬសហគ្រាសធុនតូច និងមធ្យមនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុនគ្រប់គ្រងកម្រិតនិងត្រួតពិនិត្យការប្រមូលផ្តុំហានិភ័យឥណទាននៅពេលដែលវាត្រូវបានរកឃើញ។

ក្រុមហ៊ុនប្រើប្រាស់គោលការណ៍ និងការអនុវត្តជាច្រើនដើម្បីបន្ថយហានិភ័យឥណទាន។ គោលការណ៍ដែលមានប្រសិទ្ធិភាពបំផុតក្នុងចំណោមគោលការណ៍ទាំងអស់នេះ គឺការធានាដោយដាក់វត្ថុបញ្ចាំចំពោះឥណទានផ្តល់ជូនអតិថិជនដែលជាការអនុវត្តទូទៅ។ ក្រុមហ៊ុនអនុវត្តគោលការណ៍ស្តីពីការទទួលយកនូវចំណាត់ថ្នាក់ជាក់លាក់នៃវត្ថុបញ្ចាំឬការបន្ថយហានិភ័យឥណទាន។ ប្រភេទនៃវត្ថុបញ្ចាំសំខាន់ៗ ដែលបានធានាលើឥណទានផ្តល់ជូនអតិថិជនមានដូចជា វត្ថុបញ្ចាំជាទ្រព្យសម្បត្តិ (ដី អគារ និងទ្រព្យសម្បត្តិផ្សេងៗ)។

## ៣០. គោលដៅ និងគោលការណ៍នៃការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

(១) ហានិភ័យឥណទាន (ត)

ខ. ហានិភ័យឥណទានអតិបរមាដោយមិនគិតវត្ថុបញ្ចាំឬការពង្រីកឥណទានផ្សេងៗ

| | កំណត់សម្គាល់ | ២០១៩ ដុល្លារអាមេរិក | ២០១៩ ពាន់រៀល | ២០១៨ ដុល្លារអាមេរិក |
|---|---|---|---|---|
| **ហានិភ័យឥណទានទាក់ទងនឹងទ្រព្យសកម្មក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុៈ** | | | | |
| សមតុល្យនៅធនាគារផ្សេងៗ | ៨ | ៣២៧.៧៨៥ | ១.៣៣៥.៧២៤ | ៤៤.២១៦ |
| ឥណទានអតិថិជន | ៩ | ៤.២២៦.១៨០ | ១៧.២២១.៦៨៤ | ៤.១៧៨.៤៥៩ |
| គណនីត្រូវទទួលផ្សេងៗ | ១០ | ១៦២.៣៣៣ | ៦៦១.៥០៧ | ១៧៧.២៣៥ |
| | | ៤.៧១៦.២៩៨ | ១៩.២១៨.៩១៥ | ៤.៣៩៩.៩១០ |

តារាងខាងលើនេះបង្ហាញពីស្ថានភាពអាក្រក់បំផុតនៃ ហានិភ័យឥណទានរបស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ដោយមិនគិតលើវត្ថុបញ្ចាំឬការពង្រីកឥណទានផ្សេងៗ។ ចំពោះទ្រព្យសកម្មក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុហានិភ័យដែលបានបង្ហាញខាងលើគឺផ្អែកទៅលើតម្លៃពិតគណនេយ្យសុទ្ធ។

គ. ការរឹបអូសវត្ថុបញ្ចាំ

ក្នុងកំឡុងការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ នេះក្រុមហ៊ុនមិនបានរឹបអូសទ្រព្យសកម្មផ្សេងៗដែលបានដាក់បញ្ចាំនោះទេ។

(២) ហានិភ័យអត្រាការប្រាក់

ហានិភ័យអត្រាការប្រាក់សំដៅលើការផ្លាស់ប្តូរទៅលើចំណូលអត្រាការប្រាក់សុទ្ធ ដែលជាលទ្ធផលនៃការផ្លាស់ប្តូរកម្រិតអត្រាការប្រាក់ ហើយនិងការឡើងចុះនៃសមាសភាគរបស់ទ្រព្យសកម្ម និងបំណុល។ ហានិភ័យអត្រាការប្រាក់ គឺត្រូវបានចាត់ចែងតាមរយៈការត្រួតពិនិត្យយ៉ាងល្អិតល្អន់លើផលនៃការវិនិយោគ ការកំណត់ថ្លៃទីផ្សារថ្លៃដើមនៃមូលនិធិ និងតាមរយៈការវិភាគចន្លោះភាពងាយប៉ះពាល់របស់អត្រាការប្រាក់។ ការកាត់បន្ថយជាសក្តានុពលនៅក្នុងចំណូលអត្រាការប្រាក់សុទ្ធ កើតពីចលនាអវិជ្ជមានរបស់អត្រាការប្រាក់ គឺត្រូវបានត្រួតពិនិត្យផ្ទុយពីព្រំដែននៃការអត់អោនហានិភ័យដែលបានកំណត់។ ការវិភាគនៃហានិភ័យអត្រាការប្រាក់ដែលជាប់ទាក់ទងទៅនឹងទ្រព្យសកម្មនិងបំណុលរបស់ក្រុមហ៊ុនត្រូវបានបង្ហាញខាងក្រោម។

តារាងខាងក្រោមនេះសង្ខេបអំពីរបាយការណ៍របស់ ក្រុមហ៊ុនចំពោះហានិភ័យអត្រាការប្រាក់។ តារាងនេះមានរាប់បញ្ចូលទ្រព្យសកម្ម និងបំណុលរបស់ក្រុមហ៊ុនក្នុងតម្លៃពិតដោយចំណាត់ថ្នាក់តាមថ្ងៃផ្តើមការចរចាលើអត្រាការប្រាក់ ឬថ្ងៃដល់កាលកំណត់។

## ៣០. គោលដៅ និងគោលការណ៍នៃការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ(ត)

(២) ហានិភ័យអត្រាការប្រាក់ (ត)

| | អត្រាការប្រាក់ ប្រសិទ្ធផលជាមធ្យម % | កំឡុងពេល ១ឆ្នាំ ដុល្លារអាមេរិក | ១ឆ្នាំ ដល់ ៥ឆ្នាំ ដុល្លារអាមេរិក | លើសពី ៥ឆ្នាំ ដុល្លារអាមេរិក | គ្មានការប្រាក់ ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|---|---|---|
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩** | | | | | | |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | | | |
| សាច់ប្រាក់ក្នុងដៃ | | - | - | - | ៤០.៤៧០ | ៤០.៤៧០ |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា៖ | | | | | | |
| ប្រាក់តម្កល់តាមច្បាប់ | ០,៦៣ | ១៤៥.៧៨៨ | - | - | - | ១៤៥.៧៨៨ |
| គណនីចរន្ត | | - | - | - | ១.៧០៦ | ១.៧០៦ |
| សមតុល្យនៅធនាគារផ្សេងៗ | ២,៥០ | ២៤០.០០០ | - | - | ៨៧.៧៨៥ | ៣២៧.៧៨៥ |
| ឥណទានអតិថិជន | ១៧,៩០ | ៤.៣១៤ | ៤.២២៣.១៥២ | - | - | ៤.២២៧.៤៦៦ |
| គណនីត្រូវទទួលផ្សេងៗ | | - | - | - | ១៦២.៣៣៣ | ១៦២.៣៣៣ |
| | | ៣៩០.១០២ | ៤.២២៣.១៥២ | - | ២៩២.២៩៤ | ៤.៩០៥.៥៤៨ |
| *(គិតជាពាន់រៀល)* | | *១.៥៨៩.៦៦៦* | *១៧.២០៩.៣៨៤* | - | *១.១៩១.០៩៨* | *១៩.៩៩០.១០៨* |
| **បំណុលហិរញ្ញវត្ថុ** | | | | | | |
| គណនីត្រូវបង់ផ្សេងៗ | | - | - | - | ៨៦.៤៨០ | ៨៦.៤៨០ |
| កម្ចី | ៩,៥៨ | ៤៣០.០០០ | ១.០៤៧.០៣៥ | - | - | ១.៤៧៧.០៣៥ |
| | | ៤៣០.០០០ | ១.០៤៧.០៣៥ | - | ៨៦.៤៨០ | ១.៥៦៣.៥១៥ |
| *(គិតជាពាន់រៀល)* | | *១.៧៥២.២៥០* | *៤.២៦៦.៦៦៨* | - | *៣៥២.៤០៦* | *៦.៣៧១.៣២៤* |

## ២៦. គោលដៅ និងគោលការណ៍នៃការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

(២) ហានិភ័យអត្រាការប្រាក់ (ត)

| | អត្រាការប្រាក់ ប្រសិទ្ធផលជាមធ្យម % | កំឡុងពេល ១ឆ្នាំ ដុល្លារអាមេរិក | ១ឆ្នាំ ដល់ ៥ឆ្នាំ ដុល្លារអាមេរិក | លើសពី ៥ឆ្នាំ ដុល្លារអាមេរិក | គ្មានការប្រាក់ ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|---|---|---|
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨** | | | | | | |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | | | |
| សាច់ប្រាក់ក្នុងដៃ | | - | - | - | ៣៨.៦០៤ | ៣៨.៦០៤ |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជាៈ | | | | | | |
| ប្រាក់តម្កល់តាមច្បាប់ | ០,៥៤ | ១៤៥.៧៨៨ | - | - | - | ១៤៥.៧៨៨ |
| គណនីចរន្ត | | - | - | - | ១.២១៦ | ១.២១៦ |
| សមតុល្យនៅធនាគារផ្សេងៗ | | - | - | - | ៤៤.២១៦ | ៤៤.២១៦ |
| ឥណទានអតិថិជន | ១៥,២៣ | ១២.២០៨ | ៤.១៦៩.៥៩៩ | - | - | ៤.១៨១.៨០៧ |
| គណនីត្រូវទទួលផ្សេងៗ | | - | - | - | ១៧៧.២៣៥ | ១៧៧.២៣៥ |
| | | ១៥៧.៩៩៦ | ៤.១៦៩.៥៩៩ | - | ២៦១.២៧១ | ៤.៥៨៨.៨៦៦ |
| **បំណុលហិរញ្ញវត្ថុ** | | | | | | |
| គណនីត្រូវបង់ផ្សេងៗ | | - | - | - | ១០៨.៤២០ | ១០៨.៤២០ |
| កម្ចី | ៩,០២ | ១.០៧៤.០៨៦ | - | - | - | ១.០៧៤.០៨៦ |
| | | ១.០៧៤.០៨៦ | - | - | ១០៨.៤២០ | ១.១៨២.៥០៦ |

## ៣០. គោលដៅ និងគោលការណ៍នៃការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ(ត)

(៣) ហានិភ័យសន្ទីយភាព

ហានិភ័យសន្ទីយភាព គឺពាក់ព័ន្ធនឹងសមត្ថភាពក្នុងការរក្សាទ្រព្យសម្បត្តិដែលងាយបំលែងជាសាច់ប្រាក់ ដើម្បីបំពេញនូវកិច្ចសន្យា និងកាតព្វកិច្ចហិរញ្ញវត្ថុពេលវាដល់កាលកំណត់សងក្នុងតម្លៃសមហេតុផលមួយ។ បន្ថែមទៅតាមរាល់តម្រូវការលំហូរសាច់ប្រាក់ក្រុមប្រឹក្សាភិបាល នៃក្រុមហ៊ុនត្រួតពិនិត្យយ៉ាងល្អិតល្អន់នូវរាល់លំហូរចូល និងលំហូរចេញ និងគម្លាតថ្ងៃកំណត់សងកំឡុងការិយបរិច្ឆេទ។ បម្រែបម្រួលឥណទាន និងប្រាក់តម្កល់ អតិថិជនគឺត្រូវបានពិនិត្យហើយតម្រូវការនៃសាច់ប្រាក់ងាយស្រួល ត្រូវបានកែសម្រួលដើម្បីធានាថាទ្រព្យបង្វិលជាសាច់ប្រាក់មានគ្រប់គ្រាន់ ដើម្បីបំពេញកិច្ចសន្យានិងកាតព្វកិច្ចហិរញ្ញវត្ថុនៅពេលដល់ថ្ងៃកំណត់សង។

តារាងខាងក្រោមនេះបង្ហាញអំពីការវិភាគបំណុលរបស់ក្រុមហ៊ុន ដោយមានការបែងចែកជាក្រុមទៅតាមកាលកំណត់ដោយផ្អែកទៅលើកាលបរិច្ឆេទនៅសល់រហូតដល់ថ្ងៃសង៖

| | តាមតម្រូវការឬ កំឡុងពេល ១ឆ្នាំ ដុល្លារអាមេរិក | ១ឆ្នាំ ទៅ ៥ឆ្នាំ ដុល្លារអាមេរិក | លើសពី៥ឆ្នាំ ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|---|
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩** | | | | |
| គណនីត្រូវបង់ផ្សេងៗ | ៨៦.៤៨០ | - | - | ៨៦.៤៨០ |
| កម្ចី | ៤៣០.០០០ | ១.០៤៧.០៣៥ | - | ១.៤៧៧.០៣៥ |
| | ៥១៦.៤៨០ | ១.០៤៧.០៣៥ | - | ១.៥៦៣.៥១៥ |
| *(គិតជាពាន់រៀល)* | *២.១០៤.៦៥៦* | *៤.២៦៦.៦៦៨* | - | *៦.៣៧១.៣២៤* |

| | តាមតម្រូវការឬ កំឡុងពេល ១ឆ្នាំ ដុល្លារអាមេរិក | ១ឆ្នាំ ទៅ ៥ឆ្នាំ ដុល្លារអាមេរិក | លើសពី៥ឆ្នាំ ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|---|
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨** | | | | |
| គណនីត្រូវបង់ផ្សេងៗ | ១០៨.៤២០ | - | - | ១០៨.៤២០ |
| កម្ចី | ១.០៧៤.០៨៦ | - | - | ១.០៧៤.០៨៦ |
| | ១.១៨២.៥០៦ | - | - | ១.១៨២.៥០៦ |

(៤) ហានិភ័យលើរូបិយប័ណ្ណ

ហានិភ័យលើរូបិយប័ណ្ណ សំដៅទៅលើហានិភ័យនៃការប្រែប្រួលចុះឡើងនៃឧបករណ៍ហិរញ្ញវត្ថុ ដែលកើតឡើងពីការផ្លាស់ប្តូរក្នុងអត្រាប្តូរប្រាក់រូបិយប័ណ្ណបរទេស។

ពុំមានហានិភ័យជាសារវន្តលើរូបិយប័ណ្ណទេ ពីព្រោះមានប្រតិបត្តិការភាគច្រើនជាប្រាក់ដុល្លារអាមេរិក។ វត្ថុមានសំខាន់នៃប្រាក់ដុល្លាអាមេរិក គឺជាទម្លាប់ធម្មតានៅប្រទេសកម្ពុជាដោយសារ ប្រាក់ដុល្លារអាមេរិកជារូបិយប័ណ្ណទូទាត់ដែលគេនិយមប្រើប្រាស់។

## ៣០. គោលដៅ និងគោលការណ៍នៃការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ(ត)

(៥) ការគ្រប់គ្រងមូលធន

កម្មវត្ថុចំបងរបស់ក្រុមហ៊ុនក្នុងការគ្រប់គ្រងមូលធន គឺដើម្បីអនុលោមតាមតម្រូវការរបស់ធនាគារជាតិ និងបន្តនិរន្តភាពអាជីវកម្ម ព្រមទាំងគាំទ្រដល់ការអភិវឌ្ឍអាជីវកម្មតាមរយៈការរក្សាមូលដ្ឋានដើមទុនរឹងមាំ។

តារាងខាងក្រោមនេះ សង្ខេបពីសមាសភាពដើមទុនតាមច្បាប់៖

| | ២០១៩ | | ២០១៨ |
|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ដើមទុន | ២.៩១៥.៧៦៦ | ១១.៨៨១.៧៤៦ | ២.៩១៥.៧៦៦ |
| បុព្វលាភភាគហ៊ុន | ៦៣.០៧៨ | ២៥៧.០៤៣ | ៦៣.០៧៨ |
| ដើមទុនផ្សេងៗ | ១៩០.០០០ | ៧៧៤.២៥០ | ១៩០.០០០ |
| ទុនបម្រុង | ៨៤.៤៦៨ | ៣៤៤.២០៧ | ៩៦.៦៧៧ |
| ចំណេញរក្សាទុក | ២១០.២៩៤ | ៨៥៦.៩៤៨ | ២១៥.៦៣៧ |
| | ៣.៤៦២.៦០៦ | ១៤.១១៤.១៩៤ | ៣.៤៨១.១៥៨ |

## ៣១. ពន្ធយថាភាព

ប្រព័ន្ធពន្ធដារនៅព្រះរាជាណាចក្រកម្ពុជាមានសភាពថ្មី ហើយពន្ធត្រូវបានបែងចែកជាច្រើនប្រភេទនិង បទបញ្ញត្តិមានការផ្លាស់ប្តូរញឹកញាប់ដែលជាធម្មតាពុំមានភាពច្បាស់លាស់មានភាពផ្ទុយគ្នា និងពឹងផ្អែកលើការ បកស្រាយ។ ជាធម្មតាការបកស្រាយខុសគ្នាៗច្រើនកើតមានឡើងក្នុងចំណោមអាជ្ញាធរពន្ធដារ និងយុត្តាធិការ។ ពន្ធដារ គឺជាកម្មវត្ថុនៃការពិនិត្យឡើងវិញ និងការសង្កេតដោយភ្នាក់ងារពន្ធដារផ្សេងៗជាច្រើនដែលមានសមត្ថកិច្ច ក្នុងការដាក់ពិន័យធ្ងន់ធ្ងរ និងពិន័យលើការប្រាក់។ កត្តាទាំងនេះហើយដែលអាចធ្វើឱ្យមានហានិភ័យសារពើពន្ធនៅ ក្នុងព្រះរាជាណាចក្រកម្ពុជាខ្លាំងជាងប្រទេសដទៃទៀត។ ថ្នាក់ដឹកនាំមានការជឿជាក់ថា ខ្លួនបានធ្វើសំវិធានធន បំណុលពន្ធគ្រប់គ្រាន់ដោយផ្អែកលើការបកស្រាយបទបញ្ញត្តិពន្ធរបស់ខ្លួន។ ទោះបីជាយ៉ាងនេះក្តី សមត្ថកិច្ចពន្ធ ពាក់ព័ន្ធអាចមានការបកស្រាយខុសៗគ្នាហើយអាចធ្វើឱ្យមានផលប៉ះពាល់ជាសារវន្ត។

## ៣២. ព្រឹត្តិការណ៍សំខាន់ៗបន្ទាប់ពីការបញ្ចប់រយៈពេលនៃរបាយការណ៍

អង្គការសុខភាពពិភពលោកបានប្រកាសថាជម្ងឺឆ្លងវីរុសណូវែលកូរ៉ូណា (កូវីត-១៩) ជាជម្ងឺរាតត្បាតនៅថ្ងៃ ទី១១ ខែមីនា ឆ្នាំ២០២០។ ដោយការវិវឌ្ឍន៍កើតឡើងបន្ទាប់ពីរយៈពេលរបាយការណ៍ ជំងឺរាតត្បា កូវីត-១៩ ត្រូវ បានចាត់ទុកជាព្រឹត្តិការណ៍មិនមានការកែតម្រូវ ដោយអនុលោមតាម ស.គ.អ.ក *១០ ព្រឹត្តិការណ៍ក្រោយរយៈពេល របាយការណ៍*។ ដូច្នេះរបាយការណ៍ហិរញ្ញវត្ថុសម្រាប់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ មិនមានផលប៉ះពាល់ដែលកើត ឡើងពីព្រឹត្តិការណ៍នេះទេ។

ក្រុមហ៊ុនកំពុងស្ថិតក្នុងការវាយតម្លៃថាតើជំងឺរាតត្បាត កូវីត-១៩ មានផលប៉ះពាល់ទៅលើរបាយការណ៍ ហិរញ្ញវត្ថុឬទេ ដោយសារការវិវឌ្ឍន៍របស់វាមិនទាន់មានភាពប្រាកដប្រជា និងមិនអាចព្យាករណ៍ដោយសមហេតុ ផលនាថ្ងៃដែលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុម័ត។

ក្រុមហ៊ុនបានរំពឹងទុកថាផលប៉ះពាល់ទៅលើរបាយការណ៍ហិរញ្ញវត្ថុនៃ ជំងឺរាតត្បា កូវីត-១៩ អាចនឹងត្រូវ បានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០។

## ៣៣. ការពន្យល់ពីការផ្លាស់ប្តូរមក ស.រ.ហ.អ.ក.ស.ធ.ត.ម

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ជារបាយការណ៍ដែលរៀបចំតាម ស.រ.ហ.អ.ក.ស.ធ.ត.ម ជាលើកដំបូង។ កាលបរិច្ឆេទអន្តរកាលរបស់ក្រុមហ៊ុន គឺថ្ងៃទី១ ខែមករា ឆ្នាំ២០១៨ ហើយរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុយោង រៀបចំតាម ស.រ.ហ.អ.ក.ស.ធ.ត.ម ក៏ត្រូវបានរៀបចំនៅថ្ងៃនោះដែរ។

ដើម្បីអោយអនុលោមទៅតាម ស.រ.ហ.អ.ក.ស.ធ.ត.ម គោលការណ៍គណនេយ្យត្រូវបានផ្លាស់ប្តូរ និងអនុវត្តប្រតិសកម្មដូចខាងក្រោម៖

(ក) ឱនភាពលើឥណទានអតិថិជន

ក្រុមហ៊ុនត្រូវបានគេតម្រូវឱ្យវាយតម្លៃ ថាតើមានព័ត៌មានជាក់លាក់បង្ហាញពីឱនភាពលើឥណទានរបស់អតិថិជន ឬទេ។ ប្រសិនបើមានព័ត៌មានជាក់លាក់បង្ហាញពីឱនភាព ក្រុមហ៊ុនត្រូវទទួលស្គាល់ការខាតបង់ពីឱនភាពនោះក្នុងរបាយការណ៍ចំណេញ ឬខាតភ្លាមៗ។ ក្នុងការិយបរិច្ឆេទមុន ក្រុមហ៊ុន ទទួលស្គាល់ការខាតបង់ពីឱនភាពលើឥណទានរបស់អតិថិជន ដោយផ្អែកទៅលើចំនួនថ្ងៃហួសមិនសង ដោយអនុលោមទៅតាមសេចក្តីណែនាំរបស់ធនាគារជាតិនៃកម្ពុជា។

(ខ) ថ្លៃប្រតិបត្តិការ និងការប្រាក់

ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុល ត្រូវបានទទួលស្គាល់ជាបឋមនៅតម្លៃប្រតិបត្តិការ។ ជាបន្ទាប់ត្រូវបានវាស់វែង នៅថ្លៃដើមរំលស់ដោយប្រើប្រាស់វិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព។ កម្រៃ និងកម្រៃជើងសារ ឬចំណាយជើងសារ ដែលជាផ្នែកសំខាន់នៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុល ត្រូវបានរួមបញ្ចូលក្នុងការគណនាអត្រាការប្រាក់ប្រសិទ្ធភាព។ ក្នុងការិយបរិច្ឆេទមុន កម្រៃ និងកម្រៃជើងសារ ឬចំណាយជើងសារ ដែលជាផ្នែកសំខាន់នៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុល មិនត្រូវបានរួមបញ្ចូលជាការប្រាក់ប្រសិទ្ធភាព និងទទួលស្គាល់ជាចំណូលឬចំណាយផ្សេងៗនាថ្ងៃប្រតិបត្តិការឡើយ។

ផលប៉ះពាល់នៃការផ្លាស់ប្តូរទាំងនេះទៅលើគោលការណ៍គណនេយ្យមានដូចខាងក្រោម៖

### ៣៣.១ ការផ្ទៀងផ្ទាត់របាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី១ ខែមករា ឆ្នាំ២០១៨

| | របាយការណ៍មុន | ផលប៉ះពាល់នៃការអនុវត្ត ស.រ.ហ.អ.ក.ស.ធ.ត.ម | កំណត់ឡើងវិញតាម ស.រ.ហ.អ.ក.ស.ធ.ត.ម |
|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| ឥណទានទៅអតិថិជន | ៣.៩០៧.៨៥៨ | ៧៦.៣៨៧ | ៣.៩៨៤.២៤៥ |
| គណនីត្រូវទទួលផ្សេងៗ | ១៥២.៨៤៨ | ២.២៦១ | ១៥៥.១០៩ |
| គណនីត្រូវបង់ផ្សេងៗ | (២៨.៤៥៩) | (១០.៩២៨) | (៣៩.៣៨៧) |
| ទុនបម្រុង | (៦.៩០១) | (៧៦.៣៨៧) | (៨៣.២៨៨) |
| ចំណេញរក្សាទុក | (១៥៨.៥៩៧) | ៨.៦៦៧ | (១៤៩.៩៣០) |

## ៣៣. ការពន្យល់ពីការផ្លាស់ប្តូរមក ស.រ.ហ.អ.ក.ស.ធ.ត.ម (ត)

ដើម្បីអោយអនុលោមទៅតាម ស.រ.ហ.អ.ក.ស.ធ.ត.ម គោលការណ៍គណនេយ្យត្រូវបានផ្លាស់ប្តូរ និង អនុវត្តប្រតិសកម្មដូចខាងក្រោម៖ (ត)

### ៣៣.២ ការផ្ទៀងផ្ទាត់របាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨

| | របាយការណ៍មុន | ផលប៉ះពាល់នៃការអនុវត្ត ស.រ.ហ.អ.ក.ស.ធ.ត.ម | កំណត់ឡើងវិញតាម ស.រ.ហ.អ.ក.ស.ធ.ត.ម |
|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| សមតុល្យនៅធនាគារផ្សេងៗ | ៤៣.៧៧៤ | ៤៤២ | ៤៤.២១៦ |
| ឥណទានទៅអតិថិជន | ៤.០៩៤.៦៥៨ | ៨៣.៨០១ | ៤.១៧៨.៤៥៩ |
| គណនីត្រូវទទួលផ្សេងៗ | ១៦៧.៤៦៥ | ៩.៧៧០ | ១៧៧.២៣៥ |
| គណនីត្រូវបង់ផ្សេងៗ | (៦០.៨១២) | (៤៧.៦០៨) | (១០៨.៤២០) |
| ទុនបម្រុង | (១២.៨៧៦) | (៨៣.៨០១) | (៩៦.៦៧៧) |
| ចំណេញរក្សាទុក | (២៥៣.០៣៣) | ៣៧.៣៩៦ | (២១៥.៦៣៧) |

### ៣៣.៣ ការផ្ទៀងផ្ទាត់របាយការណ៍លទ្ធផលសម្រាប់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨

| | របាយការណ៍មុន | ផលប៉ះពាល់នៃការអនុវត្ត ស.រ.ហ.អ.ក.ស.ធ.ត.ម | កំណត់ឡើងវិញតាម ស.រ.ហ.អ.ក.ស.ធ.ត.ម |
|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| ចំណូលការប្រាក់ | (៩១៨.៦៨០) | ២៩.១៧១ | (៨៨៩.៥០៩) |
| សំវិធានធនសម្រាប់ឥណទានជាប់សង្ស័យ | ៧.៧១៤ | (៧.៧១៤) | - |
| ចំណូលប្រតិបត្តិការផ្សេងៗ | (១៤.៧១៨) | (១៤២) | (១៤.៨៦០) |